ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 11-May-2017, 12:38
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្ដីនៅដំណាក់កាលពិរ

**សាធារណៈ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៥**

**ម៉ោង ០៨:៥៨នាទី**

**សវនាការលើកទី៣១៧**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន
ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*
ចៅក្រម យ៉ា សុខន
ចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន
*(Judge Jean-Marc LAVERGNE)*
ចៅក្រម យូ មណី
ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ឯម ហ៊ុយ
លោក រ៉ូជឺ ហ្វីលីព *(Mr.Roger PHILLIP)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក ស្រ៊ា រតនៈ
កញ្ញា សុង ឆវ័ន្ត
លោក ចូសេហ្វ អេនឌ្រូ ប៊ យលី
*(Mr. Joseph Andrew BOYLE)*

**ជនជាប់ចោទ៖**

លោក នួន ជា
លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ
លោក លីវ សុវណ្ណា
លោក វិចទ័រ កូប៉េ *(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោក អាកទួរ វែកកែន

*(Mr. Arthur VERCKEN)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍

*(Mr. Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍*(Ms.Marie GUIRAUD)*

លោក ឡៅ ជុនធី

លោក វ៉ែន ពៅ

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

# បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| លោក ចូសេហ្វ អេនឌ្រូ ប៊ិយលី | អង់គ្លេស |
| លោក ស្រ៊ា រតនៈ | ខ្មែរ |
| លោក អាកទួរ វែកគែន | បារាំង |
| លោក រ៉ិចឆ័រ កូប៉េ | អង់គ្លេស |
| លោក គង់ សំអុន | ខ្មែរ |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោក ពេជ អង្គ | ខ្មែរ |
| លោក ឡោ ជុនធី | ខ្មែរ |
| លោក ញឹប ហល់ (2-TCCP-269) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី៖ លោក ញឹប ហាល់** (2-TCCP-269)


សួរដោយប្រធានអង្គជំនុំ ផ្តើមពី ......... ទំព័រ ២

សួរដោយលោក ឡោ ជុនធី ផ្តើមពី ......... ទំព័រ ៤

សួរដោយលោក ពេជ អង្គ ផ្តើមពី ......... ទំព័រ ២០

សួរដោយលោក ស្រ៊ា រតនៈ ផ្តើមពី ......... ទំព័រ ២៥

សួរដោយលោក ចូសេហ្វ អេនឌ្រូ ប៊ិយលី ផ្តើមពី ......... ទំព័រ ២៨

សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្តើមពី ......... ទំព័រ ៣១

សួរដោយលោក វ៉ិចទ័រ កូប៉េផ្តើមពី ......... ទំព័រ ៣៥

សួរដោយលោក គង់ សំអុន ផ្តើមពី ......... ទំព័រ ៤២

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៨:៥៨:៣៨]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះធ្វើសវនាការស្ដាប់សក្ខីកម្មដើមបណ្ដឹងរដ្ឋប្បវេណីដែលមានរហស្សនាម 2-TCCP-269។ នៅក្នុងកិច្ចដំណើរការសវនាការស្ដាប់សក្ខីកម្មដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ មានជំនួយពីបុគ្គលិកអង្គការ ធី.ភី.អូយូ ថារ៉ាត់ អង្គុយអមដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងអំឡុងពេលគាត់ផ្ដល់សក្ខីកម្ម។

ក្រឡាបញ្ជីសវនាការ លោក ឯម ហ៊ុយ ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមាន ភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្ដីនេះ មានវត្តមាន។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការ។ លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទ នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។

ដើមបណ្ដឹងរដ្ឋប្បវេណីដែលនឹងមកផ្ដល់សក្ខីកម្មនៅថ្ងៃនេះ មានរហស្សនាម 2-TCCP-269។ ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ មានវត្តមាននៅក្នុងបន្ទប់រង់ចាំ រង់ចាំការកោះហៅពីអង្គជំនុំជម្រះ។

សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ ក្នុងបន្ទប់សវនាការរបស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៥ ដែលបញ្ជាក់ថា ដោយគាត់មានបញ្ហា

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

សុខភាព ឈឺក្បាល ឈឺចង្កេះមិនអាចអង្គុយយូរបាន មិនអាចផ្ចង់អារម្មណ៍បានយូរ និងដើម្បីមាន លទ្ធភាពចូលរួមសវនាការនៅថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការ នៅថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៥។

[០៩:០១:៣០]

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការពិនិត្យព្យាបាលថែទាំសុខភាពជនជាប់ចោទ នួន ជា នៅអ.វ.ត.ក ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៥ បានកត់សម្គាល់ថា ស្ថានភាព សុខភាពរបស់លោក នួន ជា ថ្ងៃនេះ មានអាការៈឈឺចង្កេះ វិលមុខ និងមិនអាចអង្គុយយូរបាន និងបានផ្ដល់អនុសាសន៍ថា សូមអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីបន្ទប់ខាងក្រោមសាលសវនាការនេះ។ ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះយល់ព្រម និងអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា ចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយ ស្ថិតនៅក្រោមសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

បង្គាប់ឲ្យបុគ្គលិកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅខាងក្រោមសវនាការនេះក្នុងរយៈពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

ជាបន្តទៅនេះ បង្គាប់ឲ្យមន្ត្រីរដ្ឋបាលតុលាការអញ្ជើញដើមបណ្ដឹងរដ្ឋប្បវេណី ហើយនិងបុគ្គលិកអង្គការ ធី.ភី.អូ មកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ។

*(ដើមបណ្ដឹងរដ្ឋប្បវេណីចូលក្នុងបន្ទប់សវនាការ)*

[០៩:០៣:៥៨]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្ដីលោកដើមបណ្ដឹងរដ្ឋប្បវេណី តើលោកឈ្មោះអី?

**លោក ញឹប ហល់៖**

**ឆ៖** បាទ សូមគោរពបងប្រធាន ខ្ញុំឈ្មោះ ញឹប ហល់។

**ស៖** អរគុណលោក ញឹប ហល់ តើលោកកើតថ្ងៃខែឆ្នាំណា លោកចាំដែរទេ?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** ចាំតែឆ្នាំដែលកើត។ កើតនៅឆ្នាំ១៩៥២។

**ស៖** បាទ អរគុណលោក ញឹប ហល់ តើលោកមានទីកន្លែងកំណើតនៅទីកន្លែងណា?

**ឆ៖** ខ្ញុំកើតនៅភូមិរោលជ្រូក ឃុំជប់វារី ស្រុកព្រះនេត្រព្រះ ខេត្តបាត់ដំបង បាទ។

**ស៖** បាទ អរគុណ។ ចុះទីលំនៅសព្វថ្ងៃរបស់លោក តើលោករស់នៅទីកន្លែងណា?

**ឆ៖** គឺរស់នៅភូមិ និងឃុំ ស្រុកដដែល ខេត្តបន្ទាយមានជ័យ បាទ។

**ស៖** អរគុណ។ ចុះឪពុកបង្កើតរបស់លោកឈ្មោះអី? ហើយម្ដាយបង្កើតរបស់លោក គាត់ឈ្មោះអី?

**ឆ៖** ឪពុកឈ្មោះ ញឹប រឿន។ ម្ដាយឈ្មោះ ឆាយ ឆោម។

**ស៖** ចុះប្រពន្ធរបស់លោកឈ្មោះអី ហើយលោកមានកូនប៉ុន្មាននាក់?

**ឆ៖** ប្រពន្ធឈ្មោះ ស៊ុត ដៀង កូនមានចំនួនបួននាក់ ប្រុសពីរ ស្រីពីរ។

**ប្រធានអង្គជំនុំ៖**

អរគុណ លោក ញឹម ហល់ នៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ អង្គជំនុំជម្រះបានកោះហៅលោកឲ្យចូលរួមផ្ដល់សក្ខីកម្មក្នុងឋានៈលោកជាដើមបណ្ដឹងរដ្ឋប្បវេណី។ ហើយយើងសូមជម្រាបលោកថា ក្នុងឋានៈលោកជាដើមបណ្ដឹងរដ្ឋប្បវេណី ក្រោយពីលោកផ្ដល់សក្ខីកម្ម ហើយនៅដំណាក់កាលចុងក្រោយបង្អស់នៃការផ្ដល់សក្ខីកម្មរបស់លោក គឺលោកអាចមានសិទ្ធិថ្លែងរៀបរាប់អំពីស្ថានភាពទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្មដែលកើតមានចំពោះលោកនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ប្រសិនបើលោកមានបំណងធ្វើដូច្នេះ។

បាទ ដែលអនុវត្តតាមបទប្បញ្ញត្តិនៃវិធាន៩១ ស្ទួន នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី តាំងសំណួរដេញដោលចំពោះសាក្សី ញឹប ហល់ មុនភាគីដទៃទៀតនៃរឿងក្ដី។ សូមបញ្ជាក់ថា សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី រួមទាំងសហព្រះរាជអាជ្ញាមានរយៈពេលពីរវគ្គនៃថ្ងៃសវនាការ ក្នុងការតាំងសំណួរដេញដោលចំពោះដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ។ សូមអញ្ជើញ!

[០៩:០៧:១៧]

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាននិងភាគី ខ្ញុំមេធាវីនាំមុខសូមផ្ទេរសិទ្ធិនៅក្នុងការសួរជាដំបូងជូន

លោកមេធាវី ឡោ ជុនធី សួរដើមបណ្ដឹងរដ្ឋប្បវេណី ញឹប ហល់ ហើយបន្ទាប់មកក៏ខ្ញុំនឹងសួរបន្តពីលោកមេធាវី ឡោ ជុនធី។ សូមលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។ សូមអញ្ជើញលោកមេធាវី ឡោ ជុនធី!

**លោក ឡោ ជុនធី៖**

បាទ សូមអរគុណ។ ជាដំបូងខ្ញុំបាទ សូមគោរពលោកប្រធាន សូមគោរពអង្គជំនុំជម្រះទាំងមូល ហើយសូមជម្រាបសួរលោកពូ ញឹប ហល់។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី**

**សួរដោយលោក ឡោ ជុនធី៖**

**ស៖** ខ្ញុំបាទ ឡោ ជុនធី ដែលជាមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី ហើយជាមេធាវីលោកពូដែរ ហើយខ្ញុំបាទ ជាមេធាវីនៅក្នុងអង្គការជំនួយផ្នែកច្បាប់នៅកម្ពុជា។ នៅពេលនេះខ្ញុំបាទ សូមជម្រាបសួរលោកពូអំពីដំណើរដើមទងមួយចំនួនដែលបាន ដែលលោកពូបានជួបប្រទះ ហើយនិងជាការបទពិសោធន៍ មួយនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ពីក្នុងរវាងឆ្នាំ១៩៧៥ ទៅដល់ឆ្នាំ១៩៧៩ ហើយនៅក្នុងប្រធានបទនៅពេលនេះ គឺពាក់ព័ន្ធនឹងទំនប់ត្រពាំងថ្ម។ ជាដំបូងខ្ញុំបាទសូមជម្រាបសួរលោកពូថា តើនៅមុនឆ្នាំ១៩៧៥ បន្តិច តើលោកពូរស់នៅទីណា?

**លោក ញឹប ហល់៖**

**ឆ៖** មុនឆ្នាំ១៩៧៥ គឺខ្ញុំនៅភូមិរោលជ្រូក ជាកសិករ រោលជ្រូក ឃុំជប់វារី ស្រុកព្រះនេត្រព្រះ ខេត្តបាត់ដំបង។

**ស៖** បាទ អរគុណ។ ចុះនៅពេលដែលឆ្នាំ១៩៧៥ ក្រោយពីថ្ងៃ១៧ មេសា មក តើនៅតំបន់លោកពូហ្នឹងត្រូវបានរំដោះនៅថ្ងៃហ្នឹង ឬមួយថ្ងៃណាផ្សេង?

**ឆ៖** ពេលនៅភូមិខ្ញុំ គឺរំដោះនៅថ្ងៃ១៧ មេសា បាទ។

**ស៖** ក្រោយពីរំដោះហ្នឹងហើយ តើក្រុមគ្រួសារលោកពូនៅជុំគ្នានៅទីនោះ ឬមួយគេផ្លាស់ប្ដូរពីកន្លែងលោកពូទៅណាទៀតដែរឬទេ?

**ឆ៖** បន្ទាប់មកដល់ថ្ងៃ១៧ មេសា ប្រហែលជាពីរបីថ្ងៃ គេឱ្យគេពីភូមិរោលជ្រូក គឺទៅនៅភូមិជ្រាប់ថ្មីក្នុងឃុំជប់វារី ស្រុកព្រះនេត្រព្រះដដែល។ គេឱ្យជម្លៀសចេញពីភូមិរយៈពេលបីថ្ងៃ។

**ស៖** តើនៅពេលដែលគេឲ្យជម្លៀសចេញរយៈពេលបីថ្ងៃហ្នឹង គេមានផ្តល់ព័ត៌មានទៅលោកពូថា តើគេឲ្យចេញរយៈពេលបីថ្ងៃហ្នឹង គេទៅដើម្បីអី ទៅធ្វើអី ហើយមានថាឲ្យចេញទៅទីនោះបីថ្ងៃ ហើយគេឲ្យត្រឡប់មកវិញឬមួយយ៉ាងម៉េច?

[០៩:១២:០៨]

**ឆ៖** គេឲ្យទៅរយៈពេលបីថ្ងៃ កាលណោះគេនិយាយថាខ្លាចកប៉ាល់ហោះអាមេរិកាំងមកទម្លាក់ ឲ្យចេញពីភូមិ។ ក៏នាំឪពុកម្តាយក៏នាំកូនចៅទៅតាមគេប្រាប់និងបញ្ជា ខាងខ្មែរក្រហម។

**ស៖** មានន័យថានៅពេលនោះ គឺគេជម្លៀសប្រជាជនហ្នឹងចេញអស់ពីភូមិហ្នឹងទៅភូមិជ្រាប់ថ្មីទាំងអស់គ្នា ឬមួយអ្នកខ្លះគេឲ្យទៅជ្រាប់ថ្មី ឬមួយអ្នកខ្លះគេឲ្យទៅកន្លែងណាផ្សេង?

**ឆ៖** គឺក្នុងមួយភូមិខ្ញុំហ្នឹងគឺគេឲ្យទៅនឹងភូមិជ្រាប់ថ្មី គឺទៅមួយភូមិនៅម្តុំភូមិជ្រាប់ថ្មី។

**ស៖** ហើយតើនៅពេលទៅដល់ភូមិជ្រាប់ថ្មីហ្នឹងគេ បានន័យថាគេសាងសង់ជាលំនៅដ្ឋានឲ្យនៅ ឬមួយគេធ្វើយ៉ាងដូចម្តេចដើម្បីទទួលខាងលោកពូទៅហ្នឹង?

**ឆ៖** អត់ទេ គឺយើងនៅតាមរទេះរៀងៗខ្លួន។ សម័យនោះគឺចេញទៅមានរទេះគោ ខ្លះអត់រទេះទៅ ផ្ញើអីវ៉ាន់តាមអ្នកមានរទេះគោទៅ ខ្លះគេមានរទេះក៏ផ្ញើទៅ យកតែរបស់ណាដែលស្រាលៗអាចយកទៅបាន។

**ស៖** ហើយថាតើទៅនៅទីនោះប៉ុន្មានថ្ងៃ ប៉ុន្មានខែដែរ ដែលត្រឡប់មកភូមិវិញ?

**ឆ៖** កាលណោះគេឲ្យទៅតែបីថ្ងៃទេ ប៉ុន្តែទៅៗក៏មិនឮគេថាឲ្យមកវិញក៏មិនបានមកគឺចេះតែនៅៗទៅ មិនបានមកភូមិវិញ ឮគេថា ថ្ងៃណាគេឲ្យមកវិញក៏ចេះតែនៅនឹងភូមិជ្រាប់ថ្មីទៅ។

**ស៖** ចុះមានន័យថានៅទីនោះ នៅរហូតតែម្តង ឬមួយក៏នៅត្រឹមតែប៉ុន្មាននេះ គេឲ្យទៅកន្លែងណាផ្សេងពីហ្នឹងទៀត ឬមួយយ៉ាងដូចម្តេច?

**ឆ៖** ក្នុងចំណុចនេះគឺថាខ្ញុំមិនចាំទេ ចាំតែពេលដែលគេរើសកងចល័ត ចំពោះឪពុកម្តាយគឺនៅនោះ មិនដឹងថា ដល់គេរើសកងចល័តខ្ញុំក៏ស្ម័គ្រចិត្តចូលក្នុងកកងចល័តមកច្រូតស្រូវ។

**ស៖** លោកពូថា នៅទីនោះ ហើយនៅពេលមួយគេបានជ្រើសរើសកងចល័តគេឲ្យច្រូតស្រូវ។ តើគេឲ្យទៅច្រូតនៅតំបន់ណាដែរ?

[០៩:១៦:៣៣]

**ឆ៖** ការជ្រើសរើសកងចល័ត គឺគេជ្រើសរើសឲ្យមកច្រូតនៅសាលាក្រហមក្នុងស្រុកសិរី-

សោភ័ណក្នុងចន្លោះឆ្នាំ៧៦ ខ្ញុំមិនចាំខែទេ ប៉ុន្តែដឹងថាគេជ្រើសរើសកងចល័ត។

**ស៖** ហើយតើនៅពេលនោះ លោកពូទៅតែម្នាក់ឯង ឬមួយអ្នកណាទៅជាមួយដែរ?

**ឆ៖** ខ្ញុំភ្លេចអស់ហើយ កាលនោះ ចាំតែខ្លួនឯងទៅច្រូតស្រូវប៉ុណ្ណោះ ភ្លេច។

**ស៖** ចុះនៅពេលដែលលោកពូទៅធ្វើការនៅទីនោះ តើមានសុខភាពយ៉ាងម៉េច ហើយឬមួយមានជំងឺឈឺថ្កាត់អីអត់ទេ នៅពេលនោះ?

**ឆ៖** ពេលដែលខ្ញុំទៅច្រូតស្រូវនៅសាលាក្រហម គឺថ្ងៃឡើងច្រូតស្រូវ តែយប់ឡើងត្រូវទៅលីបាវដាក់បារ៉ុងរទេះភ្លើង លីបាវស្រូវ។ សុខភាពគឺយ៉ាប់ណាស់ គឺទៅ ដូចថាទៅ ខ្លាច ទៅទាំងទឹកចិត្តខ្លាច ខ្លាចស្លាប់តែម្តង បើយើងមិនទៅ គេថាយើងតវ៉ានឹងអង្គការចាត់តាំង។

[០៩:១៩:០៥]

**ស៖** លោកពូបានលើកឡើងថា បើយើងមិនទៅ បានន័យថាប្រឆាំងនឹងអង្គការចាត់តាំង។ ចុះលោកពូបានទទួលព័ត៌មានអ្វីដែល គេថាបើមិនទៅ គេអាចធ្វើទារុណកម្ម ឬក៏អាចស្លាប់អីហ្នឹង គេ-- បានន័យថា គេផ្តល់ព័ត៌មានយ៉ាងដូចម្តេចទៅឲ្យលោកពូ?

**ឆ៖** ព័ត៌មានដែលថាមិនគោរពអង្គការចាត់តាំងគឺ ពេលដែលប្រជុំម្តងៗ គេលើកឡើងត្រូវគោរពអង្គការចាត់តាំង អង្គការចាត់តាំងទៅត្រង់ណាដាច់ខាតត្រូវតែទៅត្រង់នោះ បើមិនទៅប្រឆាំងនឹងអង្គការចាត់តាំង។

**ស៖** សូមអរគុណ។ ខ្ញុំត្រឡប់ទៅក្រោយបន្តិច គឺចំណុចដែលលោកពូលើកឡើងថាឈឺ តែខ្ញុំចង់ជម្រាបសួរថា ថាតើពេលនោះឈឺអ្វី ហើយឈឺដល់កម្រិតណា? បានន័យថា ឈឺរហូតដេកនឹងកន្ទេលតែម្តង ឬមួយយ៉ាងម៉េច? ហើយមានការព្យាបាលពីពេទ្យគេហ្នឹងដោយយកចិត្តទុកដាក់ដែរឬទេ?

**ឆ៖** ការឈឺរបស់ខ្ញុំ ដែលឈឺនៅតំបន់ដែលខ្ញុំរស់នៅសាលាក្រហម ដែលខ្ញុំលីបាវនោះ គឺធ្លាក់ឈាមចេញពីមាត់ដែលខ្ញុំលីបាវ អត់មានថ្នាំព្យាបាលទៅ យប់លីបាវ ថ្ងៃច្រូតស្រូវ មិនមានថ្នាំព្យាបាលទេ ទាល់តែសន្លប់ទៅបានគេយកមកឲ្យដេកពេទ្យ មិនដឹងដេកពេទ្យណាផង មិនដឹងមកតាមណា។ ស្រាប់ដល់ភ្ញាក់ខ្លួននៅឯពេទ្យ ធ្លាក់ឈាមចេញពីមាត់ បាទ។

[០៩:២១:៤៨]

**ស៖** ចុះនៅពេលលោកពូឈឺហ្នឹង ហើយទៅថា គេបានយកលោកពូទៅដាក់ចោលនៅកន្លែងណា មានអ៊ីចឹងដែរអត់ទេ?

**ឆ៖** ពេលនោះខ្ញុំសន្លប់បាទ ពេលដែលគេបញ្ជូនពីសាលាក្រហមឲ្យដេកពេទ្យស្រុកសិរីសោភ័ណ នោះ គឺខ្ញុំអត់ដឹងខ្លួនទេ។ ដល់ដឹងខ្លួនឡើង ដែលដឹងតាមមិត្តម្នាក់និយាយប្រាប់ គឺអ្នកស្គាល់ថា សន្លប់ ប៉ុន្មានថ្ងៃគេអូសទៅ តាមរយៈសន្លប់ពីរបីថ្ងៃបាទ។ ហ្នឹងគេយកទៅដាក់ក្នុងសាលខ្មោចនោះ ពេលធ្លាក់ ឈាមអស់ពីខ្លួនទៅអត់ដឹង ដល់-- បើនិយាយទៅសំណាងវាធ្លាក់ឈាមអស់ទៅដឹងខ្លួនមកវិញគេយក ទៅដាក់នឹងសាលខ្មោចបម្រុងនឹងយកទៅកប់ហើយបាទ។ អ្នកកប់នោះ តាមរយៈគេនិយាយប្រាប់ទេ មិត្តដែលគេឃើញ តាមរយៈគេប្រុងនឹងយកទៅកប់ ដល់កម្រើកដៃកម្រើកជើងគេយកមកវិញ។ បាទ បានរស់មកបាទ។

**ស៖** ហើយនៅពេលនោះ ក្រុមគ្រួសារលោកពូបានដឹងព័ត៌មានហ្នឹងអត់ទេបាទ?

**ឆ៖** មិនមានអ្នកណាដឹងទេ ព្រោះការទំនាក់ទំនងមនោសញ្ចេតនារវាងមនុស្ស និង មនុស្សអត់ មានទេ គឺថាវាផ្ដាច់អស់បាទ។ ផ្ដាច់ការទំនាក់ទំនងរវាងគ្រួសារ និង កូន និងចៅ មិនដឹងទៅនៅត្រង់ណា មិនដឹងស្លាប់ ឬរស់ អត់ដឹង មិនដឹងផ្ដល់ដំណឹងទៅឲ្យត្រង់ណាទេ អត់មានបណ្ដាញ អត់មានអ្នកណា នឹងផ្ដល់បាទ។

[០៩:២៤:៣២]

**ស៖** បាទ អរគុណ។ ខ្ញុំសូមចូលទៅក្នុងចំណុចសំខាន់ដែលនៅក្នុងប្រធានបទ។ នៅពេលណា ដែលគេបញ្ជូនលោកពូទៅការដ្ឋានទំនប់ត្រពាំងថ្ម លោកពូចាំទេ?

**ឆ៖** គឺពេលដែលខ្ញុំជាហើយ ប្រហែលជា១០ថ្ងៃ ចេញពីពេទ្យមកវាបញ្ជូនខ្ញុំទៅនៅចម្ការកប្បាស កងវ៉ាគាស់ឫសគុល។ ក្នុងមួយថ្ងៃពី៣០គុល ៥០គុល បាទ ចេញពីពេទ្យមកអង្គភាពពីសាលាក្រហម គេផ្លាស់មកកងវ៉ា គេបញ្ជូនខ្ញុំមកកងវ៉ា មកគាស់គុលនៅកងវ៉ា។ ខែគាស់គុល ដល់ខែ៦ បាន ឆ្នាំ៧៧ បានគេបញ្ជូនទៅត្រពាំងថ្ម ទៅរែកដី បាទ។

**ស៖** លោកពូបានលើកឡើងអម្បាញ់មិញ ពាក់ព័ន្ធនឹងថាទៅគាស់គុល បន្ទាប់មកនៅកងវ៉ា។ តើកងវ៉ាហ្នឹងនៅជិតទំនប់ត្រពាំងថ្មហ្នឹង ឬមួយយ៉ាងម៉េច? កងវ៉ាហ្នឹងស្អីគេទៅ?

**ឆ៖** កងវ៉ា គឺជាការដ្ឋានចម្ការកប្បាស បាទ សម័យបីឆ្នាំគេឲ្យដាំកប្បាស គឺចម្ការកប្បាស របស់ខ្មែរក្រហម។ បាទ គាស់គុលដើម្បីយកដីដាំកប្បាសនៅក្នុងស្រុកសិរីសោភ័ណ ខេត្តបន្ទាយមាន ជ័យ សព្វថ្ងៃ។

**ស៖** បាទ អរគុណ។ លោកពូថានៅក្នុងឆ្នាំ១៩៧៧ គេបញ្ជូនលោកពូទៅក្នុងទៅអាងត្រពាំងថ្ម

តើនៅពេលដែលលោកពូទៅដល់អាងត្រពាំងថ្មដំបូង តើលោកពូសង្កេតឃើញម្ដុំនោះ កន្លែងនោះ ឃើញទិដ្ឋភាពយ៉ាងដូចម្ដេចដែរ?

**ឆ៖** ពេលខ្ញុំទៅដល់ត្រពាំងថ្ម ទៅដល់គេបើកបង្គីនិងចបឲ្យ។ បើកបង្គីនិងចបឲ្យហើយ ក៏ព្រឹកឡើងគេទៅបង្ហាញដីឲ្យរែកនៅអាង ជើងអាងត្រពាំងថ្មហ្នឹង ស្ពានទី១បាទ។

[០៩:២៨:០០]

**ស៖** បានន័យថានៅពេលដែលលោកពូទៅដល់ភ្លាម គឺគេចែកបង្គី ចែកចប ព្រលឹមឡើងចុះទៅធ្វើក្នុងការដ្ឋានតែម្ដង សំណួរខ្ញុំចង់ជម្រាបសួរលោកពូថា នៅពេលទៅដល់ហ្នឹង តើគេរៀបចំលោកពូជាកង ជាក្រុម គេឲ្យកន្លែងស្នាក់នៅ កន្លែងណាខ្លះអ៊ីចឹង? បាទ នៅពេលនុ៎ង គឺលោកពូទៅដល់នោះឃើញមនុស្សច្រើន ឬមួយមនុស្សតិចនៅទីនោះហើយស្រេច ឬមួយទៅដល់អត់ឃើញមនុស្សទេ បាទ?

**ឆ៖** គឺទៅដល់គេធ្វើរោងឲ្យនៅស្រេច ដែលប្រក់អំពីស្បូវ ធ្វើរោងជាប់នឹងដី រោងវែងៗ បាទ នៅមួយកន្លែងដែលអាចស្នាក់នៅបាន១០០នាក់ នៅត្រពាំងថ្ម ចម្ងាយពីទំនប់ប្រហែលជា១គីឡូដែរ មកជាប់នឹងភូមិត្រពាំងថ្ម។

**ស៖** អ៊ីចឹងមានន័យថាទីតាំងដែលស្នាក់នៅហ្នឹងឆ្ងាយពីទំនប់១គីឡូម៉ែត្រ?

**ឆ៖** បាទ ឆ្ងាយពីទំនប់ប្រហែល១គីឡូម៉ែត្រដែរ។ គេមិនឲ្យនៅជាប់នឹងទំនប់នោះទេ ឲ្យនៅឲ្យឆ្ងាយ ដល់ពេលវាស់ដីបានគេឲ្យទៅ។

**ស៖** តើនៅក្នុងក្រុមលោកពូ ឬមួយកន្លែងដែលលោកពូទៅនៅហ្នឹង នៅក្រុមហ្នឹងប៉ុន្មាននាក់ដែរ?

**ឆ៖** ព្រោះក្នុងកងរបស់ខ្ញុំ មាន១០០នាក់ ជាយុវជនទាំងអស់ អត់មានវ័យកណ្ដាលលាយទេស្ត្រីក៏អត់មាន មានបុរស យុវជន ទាំង១០០នាក់។

[០៩:៣១:១៨]

**ស៖** អរគុណ។ តើលោកពូដឹងទេថានៅក្នុង១០០នាក់ហ្នឹងសុទ្ធតែយុវជនសុទ្ធសាធ ដែលមកពីភូមិតែមួយរបស់លោកពូ ឬមួយមកពីភូមិអ្នកផ្សេង ភូមិផ្សេងទៀត?

**ឆ៖** ក្នុង១០០នាក់មកពីភូមិផ្សេងៗ បាទ មកពីភូមិផ្សេងៗក្នុងតំបន់៥ហ្នឹង បើនិយាយទៅជាចល័តតំបន់តែម្ដង។ មកពីប៉ុន្មានស្រុក ក្នុងតំបន់។

**ស៖** បាទ តើលោកពូបានទំនាក់ទំនងគ្នាទេនៅក្នុង១០០នាក់ហ្នឹង ដឹងថាអ្នកដែលមកលើកទំនប់ហ្នឹងជាអ្នកដែល មានអ្នកដែលត្រូវជម្លៀសមកពីភ្នំពេញដែរឬអត់ទេ ឬមួយមានតែអ្នកដែលនៅមូលដ្ឋាន

ខាងបាត់ដំបងយើងហ្នឹង និងខាងស្រុកភូមិលោកពូហ្នឹង ឬមួយមានអ្នកផ្សេងទៀត?

**ឆ៖** ខ្ញុំក៏វាមិនចាំទេ ភ្លេចបាទ វាច្រើនឆ្នាំហើយ ក៏ភ្លេចមនុស្សអស់។ ទៅវាច្រើនតំបន់ដែរ ទាំងប្រជាជន១៧ មកពីភ្នំពេញក៏មាន ប៉ុន្តែខ្ញុំភ្លេចអស់។

**ស៖** បាទ អរគុណលោកពូ។ អម្បាញ់មិញលោកពូថា គេចែកបង្គី ចែកចបព្រលឹមទៅធ្វើការតែម្តង។ តើនរណាជាអ្នកចែកចប ចែកបង្គី ហើយនិងវាស់ដីចែកឲ្យខាងលោកពូហ្នឹង តើគាត់ចែកឲ្យក្នុងម្នាក់ៗ ឬមួយចែកឲ្យជាក្រុមធំហ្នឹងតែម្តង ឬមួយធ្វើផ្សេងពីហ្នឹង?

**ឆ៖** ទៅដល់ គឺចែកជាម្នាក់ៗបាទ ចែកម្នាក់៥ម៉ែត្រគូប គឺវាស់៥ម៉ែត្រគូបចូលទៅ។ ក្នុងម្នាក់៥ម៉ែត្រគូបទៅ បោះបង្គោលប្រវែងជម្រៅ កម្ពស់។

[០៩:៣៤:៤៣]

**ស៖** បាទ អរគុណ។ លោកពូអម្បាញ់មិញបានលើកឡើងថា ជាចែកឲ្យម្នាក់ បានន័យថាជាម្នាក់ៗ៥ម៉ែត្រគូប។ តើការវាស់វែងឲ្យលោកពូបានលើកឡើងអម្បាញ់មិញថា ៥ម៉ែត្រគូប មានប្រវែងទទឹង បណ្តោយអីចឹង ជម្រៅអីចឹង តើគេវាស់ចែក៥ម៉ែត្រគូបហ្នឹង គេវាស់យ៉ាងម៉េច? បានន័យគេវាស់ហើយគេបោះបង្គោលឲ្យម្នាក់ៗម្តង ឬមួយយ៉ាងម៉េច?

**ឆ៖** ចំពោះកងខ្ញុំ គេបោះបង្គោលឲ្យម្នាក់ៗតែម្តង បាទ ដូចថា ៥ម៉ែត្រគូបអីចេះទៅ។ គេវាស់ឲ្យម្នាក់ៗ ត្រង់ណា៥ម៉ែត្រគូប ស្រេចតែគេបោះបង្គោលត្រង់នោះហើយ យើងរែកឲ្យតែរួចទៅ បាទ ៥ម៉ែត្រគូប។

**ស៖** មានន័យថា៥ម៉ែត្រគូប វាស់ឲ្យ៥ម៉ែត្រគូបក្នុងម្នាក់ ហើយក្នុងម្នាក់ហ្នឹង ធ្វើប៉ុន្មានថ្ងៃទៅ?

**ឆ៖** អត់មានបានធ្វើច្រើនថ្ងៃទេ ធ្វើតែមួយថ្ងៃឲ្យរួចតែម្តង បាទ។ ក្នុង៥ម៉ែត្រគូបម្នាក់ គឺឲ្យរួច៥។ គឺហូបបាយ ហូបនឹងអន្លង់កន្លែងរែកដី អត់មានពិបាកដើរទៅហូបឯណា។ បាយគេយកទៅឲ្យនឹងអន្លង់នោះឯង បាទ អន្លង់ដីរែក។

**ស៖** បាទ អរគុណ។ ថាតើអ្វីដែលលោកពូបានលើកឡើងអម្បាញ់មិញ ខ្ញុំចង់ត្រឡប់ក្រោយបន្តិចពេលលោកពូទៅដល់ភ្លាម តើគេចែកឲ្យ៥ម៉ែត្រគូបហ្នឹងតែម្តង ឬមួយសន្សឹមៗ ទម្រាំយើងអាចស៊ាំបានគេឲ្យ៥ម៉ែត្រគូប?

[០៩:៣៧:៣៥]

**ឆ៖** បាទ បកមកក្រោយវិញ ថាទៅដំបូងគេឲ្យ៣ម៉ែត្រគូប ៣ម៉ែត្រគូបរួច ពីថ្ងៃម៉ោងមួយ

ម៉ោងពីររួច ឡើងដល់៥ម៉ែត្រគូប បាទ។ ឡើង ដំឡើងដល់៥ម៉ែត្រគូប។

**ស៖** អញ្ចើញមានន័យថា ពីដំបូង គេដាក់៣ម៉ែត្រគូប ៣ម៉ែត្រគូប យើងធ្វើហើយ ដូចហើយពីថ្ងៃអ៊ីចឹង គេដំឡើង១ម៉ែត្រគូប ឬមួយដំឡើងរហូតទៅដល់ ៥ម៉ែត្រគូបតែម្តង ឬមួយមានវិធីសាស្ត្រអីផ្សេងទៀត?

**ឆ៖** អត់មានវិធីសាស្ត្រអីទេ គឺថាឡើងៗ ដល់ហ្នឹង ត្រឹម៥ម៉ែត្រគូបហ្នឹងឯង។ ៣ម៉ែត្រគូបរួចពីថ្ងៃអ៊ីចឹង ដល់មើលទៅរួចពីថ្ងៃ គេឲ្យដំឡើង២ម៉ែត្រគូបទៀត។

**ស៖** បាទអរគុណ។ អ្វីដែលគេដំឡើងហ្នឹង ដោយមូលហេតុថា កងចល័តហ្នឹង គាត់មានកម្លាំងខ្លាំង ហើយគាត់អាចធ្វើទៅដល់៥ម៉ែត្រគូប។ សំណួរខ្ញុំចង់ដឹងថាអ៊ីចេះទេ ចង់ដឹងថាតើដល់ពេលដំឡើងដល់កម្រិត៥ម៉ែត្រគូបហ្នឹង សួរថាកងចល័តដែលធ្វើការនៅទីនោះ គាត់អាចធ្វើហើយទាំងអស់ទេ ហើយមានជំនួយឧបករណ៍អីខ្លះ ហើយស្ថានភាពដីហ្នឹងយ៉ាងដូចម្តេចដែរ?

[០៩:៣៩:៤៩]

**ឆ៖** គេអត់មានឧបករណ៍ឲ្យទេ គឺរែកនឹងកម្លាំង បាទ។ បង្គីដាក់សុទ្ធតែជាន់ បើមិនជាន់ឲ្យបានច្រើនទេ វាមិនរួចដី។ ដាក់ហើយជាន់ពីលើឲ្យហាប់ក្នុងបង្គីហ្នឹង បើមិនអ៊ីចុះមិនរួចដី ៥ម៉ែត្រគូប។

**ស៖** ពូថារែកទាល់តែជាន់ដាក់បង្គីជាន់ដីថែមទៀត។ តើមួយអំប្រែកហ្នឹង អាចទម្ងន់ដល់លើស៥០គីឡូទេ មើលទៅ?

**ឆ៖** បើនៅប៉ះដីស្អួតក៏បានច្រើន បើប៉ះដីធ្ងន់ក៏ធ្ងន់ដែរ ប៉ះដីសើមបាទ បើដីស្អួតរាងស្រាលបន្តិច បើប៉ះដីសើម ធ្ងន់ប្រហែលជាហាប់ម្ខាង ២០គីឡូដែរបាទ។

**ស៖** ចុះនៅពេលដែលកងចល័តដែលគាត់ធ្វើអ៊ីចឹង ចុះចំពោះលោកពូលើកហើយមុនគេ ឬមួយលើកហើយក្រោយគេក្នុង ៥ម៉ែត្រគូបហ្នឹង?

**ឆ៖** នេះវាមានពេលខ្លះវាអាចជួយគ្នា ឧទាហរណ៍ថាខ្ញុំធ្វើរួចមុន៥ម៉ែត្រគូប ដល់ម៉ោងប្រាំល្ងាចដល់ទៅៗជួយគ្នា ម្នាក់បន្តិចទៀតក៏បង្ហើយជួយបង្ហើយគ្នា។ ដល់ថ្ងៃណាយើងមិនរួចក៏គេមកជួយយើងដែរ បាទ ក្នុងក្រុម។

**ស៖** ចំណុចដែលគេកំណត់៥ម៉ែត្រគូប តើមានអ្វីដែលជាការទៀងទាត់ ពេលដែលយើងធ្វើរួចតើមេកង ឬមួយមេក្រុម ឬមួយនរណាគេមកត្រួតពិនិត្យថា យើងធ្វើរួចហើយ ៥ម៉ែត្រគូបហ្នឹង?

**ឆ៖** បាទ មានមេកងគេត្រួតពិនិត្យរាយការណ៍ឲ្យខាងប្រធានការដ្ឋាន មេកងរយ ១០០នាក់។

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

គេមកត្រួតពិនិត្យវាស់វែង មានក្រុមការងារខាងវាស់វែងដីទៀត គេមកមើល កំណត់៥ម៉ែត្រជម្រៅប៉ុន្មាន ជម្រៅ១ម៉ែត្រ ទទឹង១ម៉ែត្រ បណ្តោយ៥ទៅ រួចគេមកវាស់ បាទចប់ អាចឡើងបាន។ បើមិនរួចមិនឲ្យឡើងទេមិនអាចឡើងបាន ទាល់តែជួយគ្នាទាល់តែរួច បាទ។

[០៩:៤៣:៤៦]

**ស៖** តើជួយគ្នាទាល់តែរួចហ្នឹងជួយគ្នាប៉ុន្មាន មួយក្រុម១០០នាក់ហ្នឹង ឬមួយមួយក្រុមប៉ុន្មាន?

**ឆ៖** ក្រុមៗមានក្រុមដប់នាក់ មានកង៣០ ដែលធ្លាប់ជួយៗគ្នាខ្ញុំ ជួយតែក្រុម១០នាក់ទេ។ ឧទាហរណ៍ថា ក្រុមខ្ញុំ១០ នាក់អ៊ីចឹង វាស់ប៉ុន្មាន ម្នាក់៥ម៉ែត្រគូបទៅ ជួយគ្នាតែក្រុម១០នាក់ គឺជួយ១០នាក់ហ្នឹងឯង បាទ។

**ស៖** បាទ អរគុណ។ ចាតើនៅពេលដែលលោកពូលើកដី លើកអីហ្នឹង តើគេកំណត់ម៉ោងប៉ុន្មានដែលយើងត្រូវទៅលើក ឬមួយគេមិនកំណត់ទេថា គេចែកឲ្យហើយដឹងតែម្នាក់៥ម៉ែត្រគូប កងហ្នឹងចល័តហ្នឹងស្ម័គ្រចិត្តធ្វើប៉ុន្មានធ្វើទៅ ធ្វើពីពេលណាម៉ោងណាសម្រេចតែកងចល័ត ឬមួយគេបានកំណត់ថា ម៉ោងប៉ុន្មានដែលត្រូវចូលធ្វើទីនោះ?

**ឆ៖** គេមិនមានកំណត់ទេ គឺកំណត់តែម៉ែត្រគេហ្នុង។ យើងក្រោកពីម៉ោងបី ក្រោកទៅធ្វើម៉ោងបី ព្រឹកអ៊ីចឹងទៅ ជួនកាលម៉ោងបួន ម៉ោងប្រាំបានរួច។ នាំគ្នាដាស់គ្នាក្នុងក្រុមទៅធ្វើទៅ។ ដីយើងត្រូវទៅមើលពេលល្ងាច។ និយាយថាត្រូវក្រោកទៅធ្វើត្រង់ណេះៗ គឺមិនអាចលួចបង្ខិតបង្គោលបានទេ គឺបង្គោលគេបោះស្រេចៗ។ គេបោះហើយរួចហើយគេទៅវាស់ក្រោយទៀតមិនអាចបន្លំភ្នែកគេបានទេ។

**ស៖** ខ្ញុំចង់បញ្ជាក់ថា អ៊ីចឹងពេលល្ងាចយើងបានទៅត្រួតពិនិត្យទីតាំងដែលយើងត្រូវលើកហ្នឹងហើយ។ អ៊ីចឹងមកវិញ ព្រលឹមឡើងគឺអាចឡើងទៅប្រយុទ្ធធ្វើតែម្តង មិនបាច់ថា គេដាស់ឲ្យទៅធ្វើទេឬមួយយ៉ាងម៉េចដែរពេលព្រឹកហ្នឹង?

[០៩:៤៧:០០]

**ឆ៖** ព្រឹកឡើងគឺ គេដាស់ៗឲ្យទៅធ្វើដល់ពេលព្រឹកឡើងដាស់ទៅ។ ជួនកាលម៉ោងបួនទៅជួនកាលម៉ោងប្រាំទៅតាមអាដែង និយាយទៅទិសអង្គការគេ ស្រេចគេប្រាប់ឲ្យធ្វើម៉ោងប៉ុន្មាន យើងត្រូវតែទៅឲ្យរួច។

**ស៖** ចុះពេលដែលពាក់ព័ន្ធហៅថារបបអាហារហូបចុកវិញ។ ចាតើនៅពេលយើងឡើងទៅពីព្រឹកហ្នឹងបានន័យថាត្រូវហូបអាហារនៅកន្លែងហ្នឹងហើយ ឬមួយក៏ហូបនៅកន្លែងណាពេលព្រឹកហ្នឹង?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** គ្មានរបបពេលព្រឹកទេ អត់ មានតែពេលថ្ងៃតែម្តង អត់មានរបបព្រឹកទេ មានពេលថ្ងៃ។

**ស៖** អម្បាញ់មិញលោកពូបានលើកឡើងហើយថា មានតែពេលថ្ងៃ។ ចុះនៅពេលថ្ងៃហ្នឹងតើយើងបានរបបអាហារហ្នឹងកម្រិតប៉ុនណា បានហូបឆ្អែតគ្រប់គ្រាន់សម្រាប់កម្លាំងយើងអាចតទល់ជាមួយ៥ម៉ែត្រហ្នឹងបាន ឬអត់ទេ?

**ឆ៖** និយាយពីរឿងជីវភាព គឺហូបម្នាក់ត្រូវមួយចានត្រាំមាន់ កូនចាន ទ្រើសជាងចានចង្កឹះហ្នឹងឯង។ វាល់របបចែក ឆ្អែតមិនឆ្អែតតែប៉ុណ្ណោះឯង។

**ស៖** គេវាល់របបចែកហ្នឹងជាបាយ ឬមួយជាបបរ?

[០៩:៤៩:៥៤]

**ឆ៖** មិនមែនបាយទេ គឺថារបៀបគេហៅថាបបរជ័រស្លា បបរឈ្មោលបាទ រាងខាប់បន្តិច អត់មានបាយរឹង។

**ស៖** ហើយម្ហូបអីមានអីពិសាជាមួយដែរ?

**ឆ៖** គ្មានអីទេ បើមិនព្រលិត គឺត្រកួនប៉ុណ្ណោះ និងច្រាច់ ត្រីឆ្អើរ ស្ងោរម្ជូរ ស្លម្ជូរទៅ។

**ស៖** តើរបបអាហារប៉ុណ្ណឹងចំពោះលោកពូ បានន័យថាឆ្អែតទេ? ហើយបើឆ្អែត យើងអាចថាប៉ុណ្ណឹងអាចទ្រាំទ្របានទេ ៥ម៉ែត្រគូបហ្នឹង? ចង់ជម្រាបសួរថាតើបើយើងហូបរបបបបរមួយចានអ៊ីចឹងហើយសម្លដូចលោកពូបានលើកឡើងអម្បាញ់មិញ អ៊ីចឹងតើអាចទ្រទ្រង់កម្លាំងរាងកាយហ្នឹងបានឬអត់ទេ?

**ឆ៖** ទ្រមិនបានទេ ប៉ុន្តែធ្វើនោះ ធ្វើទាំងខ្លាចស្លាប់តែម្តង។ ធ្វើទាំងកម្លាំងចិត្ត បើកម្លាំងកាយអត់មាន។ គឺកម្លាំងខ្លាចស្លាប់ហ្នឹងតែម្តង។ មិនហ៊ានតវ៉ាជាមួយអង្គការទេ។ ធ្វើដោយកម្លាំងចិត្ត ធ្វើចិត្តដែលខ្លាចគឺត្រូវតែធ្វើ។

**ស៖** តើនៅពេលដែលលោកពូទៅធ្វើការនៅទីនោះ មានពេលណាដែលគេហៅដាច់របបទេ? អត់មានបាយពិសា ឬមួយអត់មានបបរពិសា ធ្វើៗការទៅដាច់ពេល មានដាច់ពេលអ៊ីចឹង តើមានដែរអត់ទេ?

**ឆ៖** កាលដែលនៅលើកទំនប់មិនដែលមានដាច់ទេ។ ក្រោយពីលើកដីរួចនៅធ្វើស្រែប្រាំងនោះគឺដាច់ មានពេលខ្លះខាងសេដ្ឋកិច្ចគេទៅបើកមិនបាន ក៏មកពីធ្វើការវិញទៅក៏អត់ទៅ ទាល់តែម៉ោងប្រហែលជាបួនអីបាន បានអង្ករមកហូបល្ងាចតែម្តង។ បបរហូប។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** ខ្ញុំចង់ផ្តោតថា តើនៅពេលលោកពូធ្វើនៅទំនប់នេះ លោកពូបានលើកឡើងថា បបរប៉ុណ្ណឹងវាមិនឆ្អែតទេ ហើយធ្វើដោយមានការភ័យខ្លាច តើនៅពេលនោះ មានអាចថា បើយើងមិនឆ្អែត អ៊ីចឹងយើងអាចទៅរកអីហូបជុំវិញហ្នឹងបានដែរអត់ទេ?

**ឆ៖** ទៅរកបានដែរ ពេលណាយើងរួចហើយ ឆ្លៀតទៅរកប្តុងហែលជាកន្លះម៉ោង ឬក៏បួនដប់ម្ភៃ ជីកចុះប្តុង ជាពិសេសបានរស់នឹងចុះប្តុង ចុះប្តុងវាមានជាតិផ្អែម ជីកមកបានមួយបង្វេចអីមក យប់ឡើង សម័យនោះគេហៅថា ដេកតេស្តទៅ។ បាទ តេស្តៗទៅផ្អែម ឲ្យបានឆ្អែតក្រពះ។

[០៩:៥៤:០៧]

**ស៖** បានន័យថា យើងអាចរកអីហូបបាន ហើយលោកពូបានអម្បាញ់មិញថា ចុះប្តុង "ប្តុង" ហ្នឹងស្អីគេទៅចុះប្តុងហ្នឹង?

**ឆ៖** "ប្តុង" បានវាចុះនៅហ្នឹង ចុះនៅនឹងដីស្រែយើង។ មានជាតិម្សៅ មានជាតិផ្អែម។ ចុះវាចង្កោមៗ ហៅថា "ប្តុង"។

**ស៖** ហើយតើពាក់ព័ន្ធនឹងរបបអាហារមិនគ្រប់ ហើយធ្វើឲ្យកម្លាំងថយ តើកងចល័តទាំងអស់ឬមួយផ្តោតទៅលើក្រុមលោកពូ គ្មានអ្នកណាដែលធ្លាក់ខ្លួនឈឺដោយជំងឺណាមួយទេ?

**ឆ៖** មានឈឺដែរ។ ខ្ញុំក៏ភ្លេចអស់ដែរអង្កាល់នោះ វាមានឈឺក្នុងកង ក្នុងក្រុមរបស់ខ្ញុំមានឈឺមានអីដែរ ប៉ុន្តែខ្ញុំភ្លេច រយៈពេលយូរដែរហើយ។

**ស៖** តើលោកពូនៅចាំទេ ពេលដែលឈឺអ៊ីចឹងមានពេទ្យមានអីគេទៅឲ្យថ្នាំពួកគាត់ដែលឈឺនៅនុំងទេ? ហើយតើរបបអាហារគេផ្គត់ផ្គង់ចំពោះអ្នកឈឺហ្នឹងដូចម្តេចដែរ?

**ឆ៖** ចំពោះរបបអាហារ គឺអ្នកឈឺកាលនោះ គឺគេកាត់បន្ថយខ្លះបាទ។ ឧទាហរណ៍ថា គេវាល់ឲ្យអ្នកធ្វើការពេញទៅ អ្នកឈឺក៏អាចកាចទេ ដើម្បីសល់ទុកឲ្យអ្នកធ្វើការខ្លះ ប៉ុន្តែពេទ្យមិនមានទេ មិនដឹងពេទ្យនៅឯណាទេ ឈឺ។ ភ្លេចហើយ មិនដឹងថាពេទ្យនៅកន្លែងណា។ មានកន្លែងណាមានពេទ្យ។

**ស៖** តើកងចល័តគាត់ឈឺហ្នឹង ឈឺជំងឺអីដែរបាទ ជំងឺដែលគាត់ឈឺនុំង ឈឺពាក់ព័ន្ធជំងឺអី?

**ឆ៖** ភាគច្រើន គឺឈឺដើមទ្រូងកំពុងវែកដីបាទ។ ឈឺដើមទ្រូងដែលធ្វើការធ្ងន់ ហើយជំងឺផ្សេងទៀតក៏មានបាទ ហើយខ្ញុំវាភ្លេចអស់ទៅហើយបាទ។

[០៩:៥៩:០២]

**ស៖** អ៊ីចេះ តើលោកពូនឹកឃើញទេ តើនៅពេលដែលយើងហូបអាហារ ឬមួយពិសាទឹកអីតើ

មានអនាម័យទេ ហើយវាអាចបណ្ដាលឲ្យយើងឈឺដោយសារការហូប ដូចថា ហូបអម្បាញ់មិញលោកពូថា ហូបបបុង ហូបអីផ្សេងៗអ៊ីចឹង ឬមួយយើងអត់អីហូបចេះតែប៉ះអីពិសាហ្នឹង អ៊ីចឹងបណ្ដាលឲ្យយើងឈឺអាចបង្កជាអាសន្នរោគ ឬមួយដោយសារទឹកវាមិនស្អាតអី អាហ្នឹងតើមានអ៊ីចឹងដែរអត់ទេ?

**ឆ៖** បើនិយាយទៅអារឿងមនុស្សយើងរស់នៅវាសាំធម្មជាតិហើយ ទោះបីទឹកថ្លុកក្របី ក៏ផឹកទៅមិនសូវដែលអី។ ធម្មជាតិវាបង្រៀនប៉ុន្មានឆ្នាំទៅ វាស៊ាំ បាទ។

**ស៖** អ៊ីចឹងមានន័យថាពូថាឈឺហ្នឹង ឈឺអ្នកដែលឈឺក្រោកមិនរួច គឺឈឺដើមទ្រូង? មានន័យថារែកដីធ្ងន់ពេក ថាតើមានដែលឃើញថាគាត់ក្អកមកធ្លាក់ឈាមអីទេ?

**ឆ៖** ពេលនោះខ្ញុំក៏ភ្លេចដែរ ចាំបានថាមានអ្នកឈឺដើមទ្រូង មិនដឹងថា -- ខ្ញុំវាភ្លេចអស់ហើយមិនចាំ។

**ស៖** តើលោកពូចាំទេថា នៅពេលដែលមានអ្នកឈឺធ្ងន់ ត្រូវគេបញ្ជូនចេញពីក្រុមរបស់លោកពូដែរអត់ទេ?

**ឆ៖** ពេលដែលឈធ្ងន់ គឺគេបញ្ជូនដូចខ្ញុំហើយបាទ គេបញ្ជូនចេញពីកងឲ្យមកដេកពេទ្យ តែក្រោយពេលដែលជា គឺគេបញ្ជូនទៅតាមកងវិញ។

**ស៖** ពេលដែលលោកពូបានទៅធ្វើនៅទំនប់ត្រពាំងថ្ម អាងត្រពាំងថ្មហ្នឹង តើលោកពូទៅត្រង់ហ្នឹងប៉ុន្មានខែដែរ?

**ឆ៖** បាទ គឺរយៈពេលយូរគ្រាន់ដែរ ប្រហែលជាប្រាំមួយខែដែរ។

[១០:០២:៣៨]

**ស៖** អរគុណ។ តើក្នុងរយៈពេលប្រាំមួយខែនេះ លោកពូមានពេលណាដែលបានសម្រាកទៅជួបក្រុមគ្រួសារទេ?

**ឆ៖** គ្មានពេលទេ មិនដឹងថាគ្រួសារនៅត្រង់ណាផង ព័ត៌មានក៏អត់មាន។ ព្រឹកឡើងដឹងតែរែកដី ល្ងាចឡើងដឹងតែដេកយកកម្លាំងប៉ុណ្ណឹងឯង។ អត់គិត ព្រោះថាដ៏គិតដល់គ្រួសារ ក៏មិនដឹងថាគិតតាមណា សួរអ្នកណាគេ បាទ។

**ស៖** តើនៅពេលនោះ លោកពូមានប្រពន្ធហើយនៅ?

**ឆ៖** បាទ គឺនៅយុវជនទេ បាននៅកងចល័ត អ្នកមានប្រពន្ធអត់មាននៅជាមួយទេ កងខ្ញុំ។

**ស៖** តើក្នុងរយៈពេលដែលលោកពូបាននៅទីនោះ មានបានជួបប្រទះពីការរៀបការទេនៅទីនោះ?

**ឆ៖** នៅតំបន់ត្រពាំង--

**ប្រធានអង្គជំនុំ៖**

សាក្សី -- ដើមបណ្ដឹងរដ្ឋប្បវេណីកុំអាលឆ្លើយតប។ សូមអញ្ជើញលោក វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន សូមជម្រាបសួរ។ ខ្ញុំមិនមានការជំទាស់អ្វីនោះទេ<ទៅនឹងសំណួរចុងក្រោយ> ព្រោះថាវាមានភាពពាក់ព័ន្ធទៅនឹងទំនប់ ប៉ុន្តែអ្វីដែលខ្ញុំស្ដាប់មិនទាន់គឺទៅលើបញ្ហា<ដូចតទៅ>។ ឥឡូវនេះ យើងកំពុងតែស្ដាប់សក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណី។<គាត់នៅទីនេះក្នុងឋានៈជាដើមបណ្ដឹងរដ្ឋប្បវេណីម្នាក់ប៉ុណ្ណោះ>។ ដូច្នេះក្នុងនាមគាត់ជាដើមបណ្ដឹងរដ្ឋប្បវេណី គាត់គ្រាន់តែអាចផ្ដល់សក្ខីកម្មទាក់ទងទៅនឹងរបួសស្នាមដែលគាត់ទទួល<រង>ពីការធ្វើការនៅទំនប់ត្រពាំងថ្មតែប៉ុណ្ណោះ។ ហើយខ្ញុំពិនិត្យមើល<យ៉ាងហ្មត់ចត់>ទៅលើសំណើសុំ<តាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី>របស់គាត់គឺ<ក្នុងឯកសារ> E3/5018 <ដែលបានបង្កើតបានជាលក្ខណៈវិនិច្ឆ័យពាក់ព័ន្ធ។ ក្នុងពាក្យបណ្ដឹងនោះនិយាយថា៖> “ដើម្បីឲ្យ<ស្ថានភាព>ដើមបណ្ដឹងរដ្ឋប្បវេណីអាចទទួលយកបាន គឺថាការរបួសស្នាម ត្រូវតែជាការរបួសស្នាម <(ក)>ផ្លូវកាយ ផ្លូវចិត្ត ឬមួយក៏ជាសម្ភារៈ ហើយនិង<(ខ)>ផលប៉ះពាល់មួយទៀត ត្រូវតែជាផលប៉ះពាល់<>ផ្ទាល់ខ្លួន<ពីបទឧក្រិដ្ឋ ដែលកើតមាន”>។ <ខ្ញុំអាចនិយាយខុស> ប៉ុន្តែតាមតែខ្ញុំស្ដាប់កន្លងមកហ្នឹង គឺថាដូចជាមិនបាននិយាយអំពីអ្វីទាក់ទង<នឹងការទទួលយក>គាត់<ជាដើមបណ្ដឹងរដ្ឋប្បវេណី ដែលជាប់ពាក់ព័ន្ធ>ផ្ទាល់ទៅនឹងទំនប់នោះឡើយ។ ដូច្នេះខ្ញុំចង់ដឹងថាហេតុអ្វីបានជាយើងមកស្ដាប់ដើមបណ្ដឹងរដ្ឋប្បវេណីនេះវិញ? ម៉េចមិនស្ដាប់គាត់ក្នុងនាមជាសាក្សី<ធម្មតាទៅ>? <តើនេះមិនមែនជាកិច្ចការរបស់>មេធាវីដើមបណ្ដឹង<រដ្ឋប្បវេណីទេ ឬអីដែល>គួរតែផ្ដោតទៅលើ<ផ្នែកជាក់លាក់នោះ? ជាក់ស្ដែង មិនមែនខ្ញុំជាអ្នកសម្រេចថាសួរយ៉ាងម៉េចនោះទេ> ប៉ុន្តែខ្ញុំហាក់ដូចជាវង្វេង<ហើយ> ហេតុអ្វីបានជា<បុគ្គលនេះមិនធ្វើជាសាក្សីធម្មតាដូចគេទៅ ខ្ញុំចង់និយាយថា ហេតុអ្វីបានជាគាត់ក្លាយជា>ដើមបណ្ដឹងរដ្ឋប្បវេណីទៅវិញ<?>

[១០:០៦:៥៣]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមានការកត់សម្គាល់ខ្លីមួយ។ ខ្ញុំគិតថា មេធាវីការពារក្ដី នួន ជា គួរតែអានវិធានផ្ទៃក្នុង។ គាត់ត្រូវតែយល់ថាអ្វីជាដើមបណ្ដឹងរដ្ឋប្បវេណី ហើយយើងមានវិធានអ្វីខ្លះក្នុង

ការទទួលយកដើមបណ្តឹងរដ្ឋប្បវេណី ហើយគាត់ត្រូវតែបែងចែកឲ្យដាច់គ្នា។ គាត់គួរតែដឹងតាំងពី<ក្នុងដំណាក់កាល>ស៊ើបអង្កេតឯណោះ <មិនមែនទើបមកសួរនៅថ្ងៃនេះទេ>។<អ្វីដែលសហភាតារបស់យើងទើបលើកឡើង គឺជាវិធាននៃការទទួលយកជាដើមបណ្តឹងរដ្ឋប្បវេណី។> យើងមានវិធានទទួលយកគាត់រួចមកហើយ <ហើយ>សហចៅក្រមស៊ើបអង្កេត<ក៏>បានទទួលយកគាត់ជាដើមបណ្តឹងរដ្ឋប្បវេណី ដោយសារតែគាត់មានព្យសនកម្មដែលទទួលរងអំពីឧក្រិដ្ឋកម្មដែលកើតនៅត្រពាំងថ្ម។ ដូច្នេះ <ដីកាចូលជាធរមានស្ថាពរហើយ ហើយ>គាត់មកផ្តល់សក្ខីកម្មនេះក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណីមួយរូប ដែលតាំងនាមឲ្យក្រុមដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ ដែលបានដាក់ពាក្យនៅក្នុងសំណុំរឿងនេះ។ គាត់អាចផ្តល់សក្ខីកម្មអំពីអង្គហេតុបាន។ នេះគឺជាអ្វីដែលបានកើតឡើងតាំងពីពេលបង្កើត អ.វ.ត.ក មកម្ល៉េះ។ ដូច្នេះ មេធាវីការពារក្តីគួរតែបញ្ឈប់ក្នុងការសួរតវ៉ាពាក់ព័ន្ធនឹង<គោលការណ៍ចូលរួម>របស់ដើមបណ្តឹងរដ្ឋប្បវេណីទៅ<។ មេធាវីការពារក្តីគួរ>អានវិធានផ្ទៃក្នុងទៅ <ហើយ>សូមអានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ហើយអានសាលក្រម។ គួរតែយល់<គំនិតជាមូលដ្ឋាននេះ>ដែលបានកើតឡើងតាំងពីដើមមករហូតមកដល់ពេលនេះ។

[១០:០៨:១៦]

**លោក ពេជ អង្គ៖**

បាទ សូមអរគុណលោកប្រធានដែលអនុញ្ញាតឲ្យខ្ញុំមានមតិ។ ខ្ញុំគ្រាន់តែចង់ជម្រាបបន្ថែមពីលើអ្វីដែលសហការីរបស់ខ្ញុំបានជម្រាបជូន។ វាមិនមែនជាលើកទី១ទេ ដែលដើមបណ្តឹងរដ្ឋប្បវេណីលើក -- ផ្តល់សក្ខីកម្មទៅអ្វីដែលមិនពាក់ព័ន្ធខ្លួនគាត់ដោយផ្ទាល់ មិនពាក់ព័ន្ធទៅនឹងអង្គហេតុរបស់គាត់ដោយផ្ទាល់ ឬក៏ព្យសនកម្មដោយផ្ទាល់ ហើយគាត់និយាយពីអ្វីដែលគាត់បានមើលឃើញ គាត់ជួបប្រទះផ្ទាល់នៅក្នុង -- ពាក់ព័ន្ធនឹងអង្គហេតុដែលជាវិសាលភាពនៃសវនាការយើងនេះ។ តាំងពីការចាប់ផ្តើមនៃសវនាការ ០០២/០១ រហូតមកដល់ ០០២/០២នេះទៀត រហូតទៅដល់ បើយើងនិយាយរហូតទៅដល់តាំងពីសំណុំរឿង០០១ ករណីឌុច ក៏ដូចគ្នាដែរ គឺដើមបណ្តឹងរដ្ឋប្បវេណីអាចនិយាយពីអង្គហេតុដែលមិនពាក់ព័ន្ធគាត់ផ្ទាល់ ក៏ប៉ុន្តែស្ថិតនៅក្នុងវិសាលភាពនៃសវនាការផងដែរ។ ដូច្នេះ ខ្ញុំគិតថាបញ្ហានេះមិនគួរ ចោទជាបញ្ហាឡើងវិញទេ។ ក៏ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ពាក់ព័ន្ធទៅនឹងបញ្ហាព្យសនកម្ម អង្គហេតុដែលគាត់បានទទួលរង ដើមបណ្តឹងរដ្ឋប្បវេណីក៏នៅតែ ត្រូវតែនិយាយអំពីបញ្ហានេះដូចលោក វ៉ិចទ័រ កូប៉េ បានលើកអម្បាញ់មិញនេះដែរ។ ដូច្នេះ ខ្ញុំគិតថាបញ្ហានេះមិនគួរត្រូវបានលើកសាជាថ្មីនោះទេ។ បាទ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

សូមអរគុណលោកប្រធាន។

[១០:០៩:៤៩]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោក អាកទ្វូរ វែកគែន!

**លោក អាកទ្វូរ វែកគែន៖**

សូមអរគុណលោកប្រធាន ខ្ញុំសូមលើកឡើង<យ៉ាង>ខ្លី។ ខ្ញុំសូមបញ្ជាក់ថា ការជំទាស់របស់មេធាវីការពារក្តី នួន ជា នៅពេលដែលមេធាវីដើមបណ្តឹងសួរគាត់អំពីរឿងរ៉ាវដែលគាត់មិនបាននិយាយនៅក្នុងពាក្យសុំតាំងខ្លួនរបស់គាត់ គឺការនិយាយអំពីការរៀបអាពាហ៍ពិពាហ៍។ ដូច្នេះ គាត់ជាដើមបណ្តឹងរដ្ឋប្បវេណី <>គាត់<អាចប្រឹក្សា>ជាមួយមេធាវីរបស់គាត់តាំងពីពេលព្រឹកមកហើយ, <អ៊ីចឹងវានឹងមិនមានបញ្ហាអ្វីទេ។>ខុសពីសាក្សី<ធម្មតា> គាត់<អាច>ពិក្សាគ្នាជាមួយនឹងមេធាវីរបស់គាត់ <មួយថ្ងៃ ឬនាទីចុងក្រោយ មុនពេលដែលគាត់ចូលមកក្នុងសាលសវនាការនេះ>។ ដូច្នេះមេធាវីការពារក្តី<ភ្ញាក់ផ្អើលពេល>ឃើញមេធាវី<ដើមបណ្តឹងរដ្ឋប្បវេណី លើកពីរឿងមួយទៅមួយ ជាពិសេសនៅពេល>ព័ត៌មានពាក់ព័ន្ធ<>មិនមានក្នុងពាក្យសុំរបស់គាត់។<លើសពីនេះទៀត> សាក្សីមុននេះ គាត់បាននិយាយអំពីរឿងរ៉ាវ<ដែលបានលើកឡើងកាលពីម្សិលមិញ ទំនងដូចជាជួយបំពេញចន្លោះដំណើរការសវនាការដែលបានប្រព្រឹត្តកន្លងមកពីរបីថ្ងៃហើយ។ ដូច្នេះ ខ្ញុំជឿថា ចំណុចនេះក៏អាចពន្យល់បានពីប្រតិកម្មផងដែរ។> ខ្ញុំគិតថាយើងមានអារម្មណ៍ថា អត់មានភាពខុសគ្នាទេ នៅពេលដែលគាត់ធ្វើបែបនេះហ្នឹង មើលទៅដូចជាគាត់ជាសាក្សីធម្មតាអ៊ីចឹងដែរ បើធ្វើបែបនេះនោះ គឺថាអត់មានភាពខុសគ្នាសោះ រវាងសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី។ ដូច្នេះ សូមឲ្យគាត់សួរសំណួរឲ្យវាមានអ្វីដែលពាក់ព័ន្ធទៅនឹងពាក្យសុំតាំងខ្លួនរបស់គាត់<នៅចំពោះមុខអង្គជំនុំជម្រះនេះ។> កុំឲ្យសួរអ្វីដែលនៅក្រៅពាក្យសុំរបស់គាត់នោះ។

[១០:១១:៣៩]

**ប្រធានអង្គជំនុំ៖**

យើងទំនងបើឲ្យលោកនិយាយ ប្រហែលជាលោកនិយាយ បើយើងឲ្យនិយាយវិញ ប្រហែលជាលោកអត់មានពេលនិយាយទេ។ ព្រោះអត់មានពាក្យនិយាយទេ ព្រោះយើងជឿតែម្តង។ ឥឡូវយើងឲ្យប្រាំថ្ងៃនិយាយបញ្ហាហ្នឹង ប្រហែលជាលោកមេធាវីមិនមានពេលនិយាយទេ។ ពេលវេលាត្រូវតែនិយាយ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

រកនូវខ្លឹមសារដើម្បីយកមកដោះស្រាយបញ្ហា។ មិនមែនងើប ដើម្បីងើបឈរនោះទេ។ យើងគ្រាន់តែរំឭកបញ្ជាក់ឡើងវិញថា បញ្ហាគឺត្រូវញែកឲ្យដាច់ ឬក៏ឲ្យបានច្បាស់លាស់ជាកម្រិតមធ្យមរវាងថ្នាក់ជាសាក្សី និងថ្នាក់ដើមបណ្ដឹងរដ្ឋប្បវេណី។ កាលណាចូលថ្នាក់ជាដើមបណ្ដឹងរដ្ឋប្បវេណី វាពាក់ព័ន្ធជម្រៅ វាពាក់ព័ន្ធជាសារវន្ត គឺទៅទំនាក់ទំនងនៃអង្គហេតុដែលនាំឲ្យគាត់ទទួលព្យសនកម្ម ហើយគាត់តាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី។ ចំណែកបញ្ហាដែលអង្គហេតុផ្សេងទៀត ដែលពាក់ព័ន្ធជាមួយនឹងការដឹងរបស់គាត់ជារឿងបន្ទាប់បន្សំ។ យើងមិនមែនដាក់ឲ្យគាត់ រឿងដែលគាត់ដែលដឹងជារឿងចម្បង ហើយរឿងដែលគាត់ពាក់ព័ន្ធនឹងព្យសនកម្មដែលនាំឲ្យមូលហេតុដែលគាត់តាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី យើងចាត់ទុកជារឿងបន្ទាប់បន្សំ ឬរឿងអត់ប្រយោជន៍នៅក្នុងហ្នឹងទេ។ បើដូច្នេះ គឺមេធាវី គេនិយាយត្រឹមត្រូវ។ ហើយយើងសាកសុំហៅគាត់មកថ្នាក់ជាសាក្សីទៅ! យើងសួរអំពីអង្គហេតុសុទ្ធសាធ ចាំបាច់ពាក់ព័ន្ធក្នុងឋានៈជាដើមបណ្ដឹងរដ្ឋប្បវេណីធ្វើអី? ហើយយើងឲ្យអស់លោកដំណើរការគឺចង់សួរ សំខាន់គឺពាក់ព័ន្ធជាមួយនឹងអង្គហេតុដែលនាំឲ្យគាត់ទទួលរងព្យសនកម្ម ពាក់ព័ន្ធនឹងអង្គហេតុចោទប្រកាន់ ហើយចំណែកឯរឿងផ្សេងទៀត ពាក់ព័ន្ធនឹងការដឹងរបស់គាត់នៅក្នុងជុំវិញដែលពាក់ព័ន្ធនឹងគាត់ អានោះជារឿងបន្ទាប់បន្សំដែលគាត់អាច -- បើសួរបញ្ជាក់បន្ថែមបាន។

[១០:១៣:២៩]

បញ្ហាទី២ គឺយើងកត់សម្គាល់ឃើញថា តាំងសំណួរគឺច្រើនឆ្នាំហើយ ប៉ុន្តែបច្ចេកទេសវិធីសាស្ត្រក្នុងការតាំងសំណួរ វានៅតែអាចប្រាសចាកនូវសំណួរដែលអង្គជំនុំជម្រះហាមឃាត់ យើងអត់ធ្មត់មិនចង់ធ្វើការដោះស្រាយបញ្ហាហ្នឹងច្រើនពេកទេ វាដូចជាញឹកញាប់ពេក អាចធ្វើឲ្យរំខានដល់ពេលវេលាក្នុងការដំណើរការដែរ។ ជួនកាល យើងធ្វើសេចក្ដីសន្និដ្ឋាននោះ យើងសួរសាក្សី សួរដើមបណ្ដឹងរដ្ឋប្ប-វេណី វាអត់ត្រូវទេ។ យើងសួរបញ្ជាក់អង្គហេតុឲ្យគេឆ្លើយ! ហើយយើងសួរនេះ យើងមើលកត់សម្គាល់ទំនងជាមើលតាមពេលវេលាបែងចែកឲ្យ ឮតែមួយថ្ងៃ ឬក៏មួយព្រឹកនោះ គឺយើងសួរធ្វើម៉េចឲ្យអូសពេល ឲ្យអស់ពេលទេ វាមិនមានខ្លឹមសារអីស៊ីជម្រៅដើម្បីឲ្យវាយកទៅស្វែងរកការពិត សំដៅរកស្វែងរកការពិត មិនមែនសួរដើម្បីសួរឯណា សួរដើម្បីដេញដោលដើម្បីស្វែងរកការពិត។ នេះជាគោលដៅនៃសវនាការ។

ឥឡូវដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងដប់កន្លះ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។ ហើយមន្ត្រីរដ្ឋបាលតុលាការ

សម្របសម្រួលផ្តល់កន្លែងសម្រាកសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ នៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់ រួមទាំងបុគ្គលិកអង្គការ ធី.ភី.អូ មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះ។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១០:១៥ នាទី ដល់ម៉ោង ១០:៣១ នាទី)*

[១០:៣១:២៨]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយផ្តល់វេទិកាជូនទៅក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីមានឱកាសបន្តតាំងសំណួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។ ហើយបញ្ជាក់ថាដើមបណ្តឹងរដ្ឋប្បវេណី រួមទាំងសហព្រះរាជអាជ្ញាមានពេលមួយវគ្គសវនាការទៀតប៉ុណ្ណោះនៅព្រឹកនេះ។

អញ្ជើញតាំងសំណួរសារធាតុទៅ ហើយបើមានបញ្ហាអីដាក់ឯកសារជាលាយលក្ខណ៍អក្សរមកដើម្បីយើងដោះស្រាយបញ្ហានេះ ជាផ្លូវការតែម្តង។

**<លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖>**

លោកប្រធាន យើងនឹងដាក់សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរពាក់ព័ន្ធទៅនឹងអ្វីដែលបានលើកឡើងមុនពេលសម្រាកនេះ។ ខ្ញុំសូមឲ្យមានការកត់ត្រាក្នុងប្រតិចារឹកថា យើងសូមយោងទៅលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះគឺលេខ E315/1 ដែលក្នុងសេចក្តីសម្រេចនោះ អង្គជំនុំជម្រះទទួលស្គាល់ថា ដើមបណ្តឹងរដ្ឋប្បវេណីអាចផ្តល់សក្ខីកម្មអំពីអង្គហេតុនិងការឈឺចាប់បាន។ នេះជាលក្ខណៈច្បាស់ណាស់ ហើយវាជាយុទ្ធសាស្ត្ររបស់អង្គជំនុំជម្រះនេះ។ ដូច្នេះអ្វីដែលបានកើតឡើងនៅមុនពេលឈប់សម្រាកនេះ គឺជាការប្រែប្រួលក្រឡាស់ទាំងស្រុងពីអ្វីដែលយើងបានសម្រេចពីមុន<។ ខ្ញុំកត់សម្គាល់ឃើញថា> មេធាវីការពារក្តីបានស្នើសុំឲ្យដើមបណ្តឹងរដ្ឋប្បវេណីលើកឡើងអំពីព្យសនកម្ម <ហើយក្នុងពេលជាមួយគ្នានឹង ឲ្យនិយាយផ្ទុយទាំងស្រុងវិញ-->

**ប្រធានអង្គជំនុំ៖**

ឲ្យដាក់ឯកសារជាលាយលក្ខណ៍អក្សរមកណ៎ះ! បានហើយ!

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ប្រគល់តួនាទីឲ្យទៅនិយាយពីនីតិសារធាតុបន្តទៅមុខទៀត!

[១០:៣៣:៤៥]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ <ខ្ញុំគ្រាន់តែចង់បង្ហាញពីការខ្វែងគំនិតរបស់ខ្ញុំប៉ុណ្ណោះ។>

**ប្រធានអង្គជំនុំ៖**

សួរទេហ្នឹង?

**លោក ពេជ អង្គ៖**

បាទ សូមអរគុណលោកប្រធាន ខ្ញុំនឹងសួរបន្តទៅដើមបណ្តឹងរដ្ឋប្បវេណី ញឹប ហល់ បន្តទៀត។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោក ពេជ អង្គ៖**

**ស៖** បាទ សូមគោរពលោកដើមបណ្តឹងរដ្ឋប្បវេណី ញឹប ហល់! ខ្ញុំបាទមេធាវី ពេជ អង្គ មេធាវីជាតិនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។ ខ្ញុំមានសំណួរបន្តពីលោកមេធាវី ឡៅ ជុនធី ពាក់ព័ន្ធទៅនឹងការងារនៅទំនប់ត្រពាំងថ្ម ដែលលោកពូរស់នៅទីនោះផ្ទាល់ ហើយបានធ្វើការងារនៅទីនោះ។ លោកពូបានមានប្រសាសន៍ថា មានការឲ្យកាប់ដីរហូតដល់៥ម៉ែត្រគូប -- ពី៣ ដល់៥ម៉ែត្រគូប។ លោកពូអាចបញ្ជាក់បានទេ ថាតើលោកពូធ្វើយ៉ាងដូចម្តេចដើម្បីអាចសម្រេចការរែកដីឲ្យបានតាមផែនការតម្រូវ?

**លោក ញឹប ហល់៖**

**ឆ៖** បាទ ពី ៣ទៅ៥ម៉ែត្រគូប គឺបើនិយាយអ្នកដែលធ្លាប់ធ្វើ គឺអាចធ្វើកើត អ្នកមិនធ្លាប់ធ្វើវាច្រើនណាស់បាទ។ គឺសាំនឹងការងារ គឺអាចធ្វើរួច បើអ្នកមិនធ្លាប់ធ្វើគឺដូចច្រើនណាស់ ៥ម៉ែត្រគូបច្រើនបាទ។ សព្វថ្ងៃមនុស្សយើងធ្វើអត់កើតទេ--

**ស៖** ខ្ញុំសូមកាត់លោកពូ សូមឆ្លើយត្រឹមសំណួរខ្ញុំបានហើយ។ លោកពូចម្ងាយពីកន្លែងដែលពូកាប់ដី ឬក៏ពីកន្លែងកាប់ដីទៅកន្លែងចាក់ដី ថាតើចម្ងាយប៉ុន្មានម៉ែត្រ ហើយលោកពូធ្វើយ៉ាងម៉េចដើរ ឬក៏យ៉ាងម៉េចពីកន្លែងកាប់ដីទៅកន្លែងចាក់ដី លោកពូអាចជម្រាបបានទេ?

**ឆ៖** បាទ ពីកន្លែងអន្លង់ជីកដីទៅកន្លែងចាក់ប្រហែលជា ៣០ ទៅ ៥០ម៉ែត្របាទ។

**ស៖** តើជាដីស្មើ ឬក៏ខ្ពស់ទាប?

**ឆ៖** គឺដីឡើងលើខ្នងទំនប់ ឡើងៗដីជម្រាលបាទ មិនចោទទេ ឡើងបញ្ឆិតតាមជើងទំនប់។

[១០:៣៧:២២]

**ស៖** នៅពេលរែកហ្នឹង ពូរែកដើរធម្មតា ឬយ៉ាងណា?

**ឆ៖** រែកដីធម្មតាឡើងមិនរួច ទាល់តែរត់បាទ។ យក រត់យកសន្ទុះបាទ។ បើមិនរត់ឡើងមិនរួច បាទ ខ្ពស់គ្រាន់ដែរ។

**ស៖** បាទ សូមអរគុណលោកពូ។ ការងារលោកពូធ្វើនៅទីនោះ តើមានការប្រជុំទេ មានការប្រជុំថ្នាក់ដឹកនាំលោកពូ ហើយនិងក្រុមរបស់លោកពូដែលធ្វើការងារហ្នឹងដែរទេ?

**ឆ៖** ការប្រជុំ គឺប្រជុំជាញឹកញាប់ដែរ ដើម្បីទទួលផែនការផ្សេងៗ។

**ស៖** តើលោកអាចបញ្ជាក់បានទេ ញឹកញាប់ហ្នឹង ថាតើញឹកញាប់ប៉ុនណា រយៈពេលប៉ុន្មានថ្ងៃ ប៉ុន្មានសប្តាហ៍ ឬក៏ប៉ុន្មានខែម្តង?

**ឆ៖** នៅនោះវាគេចែកមានពួក បីនាក់។ វាមានក្រុម១០នាក់ ជួនកាលប្រជុំពួក ជួនកាលប្រជុំក្រុម ជួនកាលប្រជុំកង៣០។ វាមិនជាញឹកញាប់ទេ ប៉ុន្តែវាច្រើនកន្លែង បាទច្រើនក្រុម ច្រើនកង ដូចតែញឹកញាប់ដែរ។

**ស៖** តើការប្រជុំហ្នឹង ក្រៅអំពីការដាក់ផែនការ គេមាននិយាយអ្វីផ្សេងទៀតដែរឬទេ? មានការនិយាយលើកទឹកចិត្តដើម្បីលោកពូខំធ្វើដែរឬទេ?

[១០:៣៩:៥៥]

**ឆ៖** ការដែលប្រជុំ គឺលើក មិនដែលលើកឡើងអារឿងទឹកចិត្តទេ គេឲ្យតែយើងប្តេជ្ញាចិត្តតែប៉ុណ្ណោះឯង។ ដាក់ផែនការឲ្យមកថា រែកដីទៅ ក៏ទៅធ្វើរួចក៏រួច ប្តេជ្ញា គេឲ្យយើងតែប្តេជ្ញាចិត្តធ្វើឲ្យកើត ធ្វើឲ្យរួច។ រែកដី រែកឲ្យរួច។

**ស៖** តើលោកពូមានសិទ្ធិនៅក្នុងការមិនធ្វើការ មិនរែកដីហ្នឹងដែរឬទេ?

**ឆ៖** មិនមានទេ មិនមានសិទ្ធិថាមិនរែកទេ។ បើថាឈឺ មានតែទៅដេកពេទ្យ មិនដឹងថាពេទ្យនៅត្រង់ណាផង។ មិនដែលស្គាល់ពេទ្យទេនៅត្រពាំងថ្ម មិនដឹងពេទ្យនៅត្រង់ណា។

**ស៖** តើនៅក្នុងពេលនោះ លោកពូមានសិទ្ធិក្នុងការដើរទៅណា ដើរទៅលេងអ្នកណា ឬក៏ដើរជួបមិត្តភក្តិ ជជែកជាមួយមិត្តភក្តិដែរឬទេ? ឬក៏ដើរលេង មានសិទ្ធិទេ?

**ឆ៖** ព្រោះការដើរលេង ដូចមិនមានពេលទេ គឺរកតែពេលសម្រាកដើម្បី គឺយប់ឡើងគិតតែពី

រឿងថា ព្រឹកឡើងរែកតែដី ធ្វើម៉េចឲ្យបានរួច ហើយនិងរកពេលឆ្លៀតទៅជីកប្តុង ជីកអីខ្លះរយៈពេលមួយម៉ោង ដើម្បីយកមកបំពេញក្រពះ បាទ។ អត់មានគិតថា អ៊ូ! ចង់ដើរទៅលេងរកមិត្តភក្តិ ម៉ែឪ សួរមិនមានទេ អត់។

**ស៖** តើលោកពូមានសិទ្ធិជជែកជាមួយអ្នកធ្វើការជាមួយគ្នាដែរឬទេ?

**ឆ៖** មិនមានជជែកលេងទេ ការងារដឹងថាការងារ អត់មានលេងឡិកឡក់បានទេ។ រែកដីគឺរែករៀងខ្លួន។

**ស៖** បាទ អរគុណច្រើន។ ខ្ញុំចូលទៅដល់ពីបញ្ហាភ្ញៀវ ឬក៏គណៈប្រតិភូដែលមកទស្សនានៅការដ្ឋាននោះ។ តើលោកពូមានធ្លាប់ឃើញមានភ្ញៀវ ឬក៏ថ្នាក់ដឹកនាំណាមកទស្សនា ឬក៏មានកម្មវិធីអ្វីនៅទំនប់ត្រពាំងថ្មដែរឬទេ?

**ឆ៖** ចំណុចនេះខ្ញុំមិនចាំពេលវេលាទេ ដឹងថាមានម្តងគេឲ្យទៅឈរតម្រង់ជួរ យុវជនមួយចំហៀង នារីមួយចំហៀង ចាប់ពីមាត់ភូមិត្រពាំងថ្ម ទៅដល់អាងត្រពាំងថ្មស្ពានទី១ហ្នឹងម្តង បាទ។ មិនដឹងថាភ្ញៀវខាងណាទេ។ បានមានម្តង។

[១០:៤៣:៥៨]

**ស៖** តើលោកដឹងថា ភ្ញៀវហ្នឹងស្លៀកពាក់យ៉ាងដូចម្តេចទេ?

**ឆ៖** មិនដឹងទេ ខ្ញុំមិនហ៊ានមើលមុខវាផង។ គេទៅឈរក៏ឈរ មិនហ៊ានមើលមុខគេទេ។

**ស៖** តើភ្ញៀវហ្នឹងមានគ្នាច្រើនដែរឬទេ? ហើយលោកពូអាចបញ្ជាក់បានទេ វាជាពេលហ្នឹងវាជាកម្មវិធីអ្វី លោកពូអាចបញ្ជាក់បានទេ?

**ឆ៖** គេថាមានភ្ញៀវមកទស្សនកិច្ចអាង។ ខ្ញុំក៏មិនដឹងដែរ ឃើញតែឡាន ឡានខ្មៅៗ ខ្ញុំមិនបានដឹងថានរណានរណីទេ ថាភ្ញៀវមកឲ្យឈរទទួលក៏ទទួលគេទៅ។

**ស៖** តើពេលនោះមានការស្រែកជយឃោសដែរឬទេ?

**ឆ៖** ខ្ញុំភ្លេច ចាំមិនបានទេ ចាំអត់បាន។

**ស៖** លោកពូមានប្រសាសន៍ថា មានការឲ្យមកឈរតម្រង់ជួរ តើគេឈរតម្រង់ជួរយ៉ាងដូចម្តេចដែរលោកពូមាន អាចបញ្ជាក់ពីបញ្ហាហ្នឹងបានដែរឬទេ? ហើយមានពីណាគេប្រាប់ឲ្យតម្រង់ជួរយ៉ាងដូចម្តេចដែរឬទេ?

**ឆ៖** តម្រង់ជួរ នារីម្ខាងផ្លូវទៅ យុវជនម្ខាងផ្លូវម្នាក់ ភ្ញៀវគេបើកឡានដើរកណ្តាលទៅ យើង

គិតតែទះដៃទៅ ខ្ញុំវាមិនចាំទេ មិនដឹងគេឲ្យស្រែកជយឃោសអី មានប៉ុន្តែអត់ចាំ។

**ស៖** បាទ ក៏ប៉ុន្តែខ្ញុំចង់និយាយអំពីជួរ ថាតើលោកពូឈរមុខក្រោយគ្នាយ៉ាងដូចម្ដេចលោកពូ? លោកពូឈរនៅមុខ ឬក៏នៅក្រោយពេលនោះ? ហើយគេឲ្យអ្នកផាត់ អ្នកស្គមឈរយ៉ាងម៉េចដែរ លោកពូអាចបញ្ជាក់បានទេ?

**ប្រធានអង្គជំនុំ៖**

ដើមបណ្ដឹងរដ្ឋប្បវេណី កុំអាលទាន់ឆ្លើយតប! អញ្ជើញលោក វ៉ិចទ័រ -- លោក អាកឡូវ វ៉ែកគែន!

**លោក អាកឡូវ វ៉ែកគែន៖**

បាទ លោកប្រធាន ខ្ញុំសូម<>ទាញការចាប់អារម្មណ៍របស់អង្គជំនុំជម្រះទៅលើបញ្ហាដែលមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីកំពុងតែសួរនាំនេះ។ យើងកំពុងតែស្ថិតនៅក្នុងស្ថានភាពមួយដ៏ពិសេស<។ ក្នុងសវនាការក្នុងប្រទេសបារាំង នៅពេលដែល>ដើមបណ្ដឹងរដ្ឋប្បវេណីដែលទទួលស្គាល់ដោយចៅក្រមស៊ើបអង្កេត <ចៅក្រមស៊ើបអង្កេតនៅតែមានសិទ្ធិសួរដើមបណ្ដឹងរដ្ឋប្បវេណីរូបនោះបានដែរ។ នៅទីនេះ នៅក្នុងសវនាការនេះ> ដើមបណ្ដឹងរដ្ឋប្បវេណីដែលមកផ្ដល់<សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះថ្ងៃនេះ> គឺមិនទាន់មានការ<>សួរ<ចម្លើយ>ពីសហចៅក្រមស៊ើបអង្កេតទេ<។ ដូច្នេះ រាល់អ្វីដែល> គាត់បាន<បរិយាយ មិនត្រូវបាន>សរសេរ<ចូលទៅ>ក្នុងពាក្យសុំ<តាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី>របស់គាត់<នោះទេ>។<យើងទើបតែដឹងក្នុងពេលនេះ។> ខ្ញុំយល់ឃើញថា ដោយសារតែចៅក្រមស៊ើបអង្កេតមិនទាន់បានសួរគាត់ ដូច្នេះការដែលគាត់ឆ្លើយជាមួយនឹងមេធាវីរបស់គាត់ដូចជា<មាន>បញ្ហា<។ ត្រង់នេះ ខ្ញុំដូចជាមិនយល់សោះ ថាយ៉ាងម៉េចបានជាអង្គជំនុំជម្រះអនុញ្ញាតឲ្យគាត់ – ខ្ញុំនិយាយដោយគោរព – គឺអនុញ្ញាតឲ្យគាត់ឡើងមកនិយាយអំពីរឿងរ៉ាវដែលគាត់មិនបានលើកឡើង>នៅក្នុងពាក្យសុំរបស់គាត់<>។

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណី សួរតាមអ្វីដែលបច្ចេកទេសរបស់លោកសួរទៅមិនមានបញ្ហាទេ នោះគ្រាន់តែជាគាត់កត់សម្គាល់ដែលមិនត្រឹមត្រូវទេ លោកមេធាវី វ៉ិចទ័រ -- លោកមេធាវីអន្តរជាតិការពារក្ដីលោក ខៀវ សំផន នោះ លោកទៅមើលឯកសារពាក់ព័ន្ធឡើងវិញ ហើយនិងវិធានផ្ទៃក្នុង ហើយការតម្រង់ទិសហ្នឹងគឺត្រឹមត្រូវហើយ ព្រោះអង្គហេតុដែលគាត់សួរដេញដោលនេះជាប់ពាក់ព័ន្ធជាមួយនឹងអង្គហេតុដែលគាត់បង្ហាញថាគាត់ហ្នឹងពាក់ព័ន្ធនាំឲ្យគាត់តាំងខ្លួនជាដើមបណ្ដឹង

រដ្ឋប្បវេណី។

[១០:៤៨:៥០]

**សួរដោយលោក ពេជ អង្គ៖**

**ស៖** បាទ លោកពូមាននៅចាំសំណួរខ្ញុំទេ ខ្ញុំសួរសាជាថ្មី។ ថាតើក្នុងក្រុមលោកពូដែលលោកពូនៅទីនោះ តើការតម្រង់ជួរ គេធ្វើយ៉ាងដូចម្តេច? មានអ្នកមុខ អ្នកផាត់ អ្នកស្គម គេឲ្យឈរយ៉ាងដូចម្តេច ហើយពូឈរនៅកន្លែងណា? តើពូអាចបញ្ជាក់ពីបញ្ហាហ្នឹងបាននៅពេលដែលឈរទទួលគណៈប្រតិភូហ្នឹង?

**លោក ញឹប ហល់៖**

**ឆ៖** បាទ គឺគេកំណត់អ្នកស្គមអត់ឲ្យមកពីរោងទេ ព្រោះមកពីកន្លែងស្នាក់នៅទេ អ្នកឈឺអ្នកអីអត់ គេយកតែអ្នកកាយសម្បទាមាំមួន អ្នកផាត់អីមកឈរនៅផ្លូវហ្នឹង។ មនុស្សឈឺគឺនៅក្នុងរោង បាទ។

**ស៖** តើអ្នកណាជាអ្នកកំណត់យ៉ាងដូច្នេះ?

**ឆ៖** គឺអ្នកទទួលខុសត្រូវក្នុងការដ្ឋានសំណង់ស្ពានទី១ត្រពាំងថ្មហ្នឹង គេកំណត់យកមនុស្សដែលឈរទទួលភ្ញៀវរកមនុស្សដែលមានសមសួន កាយសម្បទាមាំមួន បាទ។

**ស៖** បាទ សូមអរគុណលោកពូ។ លោកពូអាចមានប្រសាសន៍ខ្លីៗបានទេ ខ្ញុំនឹងមិនមានពេលច្រើនទៀតទេ។ លោកពូនៅពេលនោះលោកពូមានស្បែកជើង មានខោអាវស្លៀកពាក់ផ្ទាល់ខ្លួនដែរឬទេ?

**ឆ៖** កាលដែលទទួលភ្ញៀវនោះ គេបើកខោអាវមួយសម្រាប់។

**ស៖** សូមទោសលោពូ ខ្ញុំគិតថាសំណួរខ្ញុំប្រហែលជាសួរលោកពូមិនត្រឹមត្រូវ។ នៅពេលដែលលោកពូនៅត្រពាំងថ្ម តើលោកពូមានស្បែកជើង មានខោអាវស្លៀកពាក់សមរម្យដែរឬទេ ពេលធ្វើការហ្នឹង?

**ឆ៖** គឺមានស្បែកជើងកង់ឡាន ខោអាវមានតែមួយកំប្លេ ហើយភួយៗបាវៗពណ៌លឿង បាទ។ មិនមានទេ មិនមានភួយដណ្តប់។

**ស៖** តើពសម្រាន្តយ៉ាងម៉េចដែរ មានគ្រែ? មានជម្រកអីត្រឹមត្រូវទេ? មានគ្រែសម្រាប់សម្រាន្តដែរឬទេ?

**ឆ៖** មានរនាបឫស្សីជាប់នឹងដី អត់ខ្ពស់ ជាប់នឹងដីដាក់ឈើកល់ទៅ វែងពីរល្វីទៅ បាទ។

[១០:៥២:៣៣]

**លោក ពេជ អង្គ៖**

អ៊ីចឹងខ្ញុំអស់សំណួរត្រឹមនេះហើយ ខ្ញុំសូមអរគុណលោកពូដែលបានឆ្លើយ ហើយខ្ញុំសូមបញ្ចប់សំណួរខ្ញុំត្រឹមនេះ។ សូមអរគុណលោកប្រធានចំពោះការផ្តល់ឱកាសឲ្យខ្ញុំសួរសំណួរនេះ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

ជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមតំណាងសហព្រះរាជអាជ្ញាដើម្បីមានឱកាសសួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។

**លោក ស្រ៊ា រតនៈ៖**

សូមគោរពលោកប្រធាន លោកចៅក្រម លោក លោកស្រីចៅក្រម និងភាគីទាំងអស់ដែលមានវត្តមាននៅទីនេះ។

[១០:៥២:១០]

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក ស្រ៊ា រតនៈ៖**

**ស៖** សូមជម្រាបសួរលោកដើមបណ្តឹងរដ្ឋប្បវេណី។ ខ្ញុំបានឈ្មោះ ស្រ៊ា រតនៈ ជាសហព្រះរាជអាជ្ញារងជាតិនៃការិយាល័យសហព្រះរាជអាជ្ញានៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ ពីមុននេះលោកបានឆ្លើយជម្រាបជូនទៅអង្គសវនាការថា លោកទទួលបានផែនការ៥ម៉ែត្រគូប ក្នុងមួយថ្ងៃ។ ដោយខ្ញុំខ្លាចលោកភ័ន្តច្រឡំនឹងសំណួរខ្ញុំៗសូមរំឭកឡើងវិញបន្តិច។ បើតាមខ្ញុំចាំមិនខុសទេ គឺទៅដល់ដំបូងលោកទទួលបានផែនការផ្សេង គឺមិនមែន៥ម៉ែត្រគូបហ្នឹងទេ។ អ៊ីចឹងខ្ញុំចង់សួរបញ្ជាក់ថា តើផែនការ៥ម៉ែត្រគូបនេះ លោកទទួលបន្ទាប់ពីផែនការទី១ហ្នឹងរហូត ឬក៏ទទួលក្នុងរយៈពេលណាមួយ? បានន័យថាជាផែនការពិសេស?

**លោក ញឹប ហល់៖**

**ឆ៖** បាទ ផែនការដែល៥ម៉ែត្រគូបនេះ គឺផែនការពិសេសដែលចាក់ត្រចៀកស្ពានទី១។ ទៅដំបូង គឺ៣ម៉ែត្រគូប ធម្មតា។ ៥ម៉ែត្រគូបគឺចាក់ត្រចៀកស្ពានខាងជើង ត្រចៀកស្ពានទី១ត្រពាំងថ្មបាទ។

**ស៖** លោកធ្វើ៥ម៉ែត្រគូបហ្នឹងក្នុងរយៈពេលប៉ុន្មានដែរ ដែលលោកលើកឡើងថាជាកាលៈទេសៈពិសេសហ្នឹង?

**ឆ៖** លក្ខណៈនោះក៏ខ្ញុំក៏មិនចាំប៉ុន្មានដែរ ប៉ុន្តែដឹងថាបានរែក៥ម៉ែត្រគូបរួចតែម្តង មិនដឹងរយៈពេលប៉ុន្មាន ខ្ញុំភ្លេច។

**ស៖** យូរ ឬឆាប់?

**ឆ៖** គឺមួយស្មើពេញ មួយត្រចៀកស្ពានដែលគេរៀបបេតុង បេតុងទប់បាទ។

**ស៖** តើនៅពេលហ្នឹងស្ថានភាពការងាររបស់លោកយ៉ាងម៉េចដែរ ចង់សំដៅទៅលើការលំបាកខុសពីអ្វីដែលលោកទទួលបាននៅក្នុងផែនការធម្មតាម៉េចដែរ?

**ឆ៖** ពេលនោះឯងដែលថា ត្រូវក្រោកពីយប់បាទ ពីម៉ោងបីបានរួច ៥ម៉ែត្រគូប។ ម៉ោងបីទល់តែម៉ោងប្រាំល្ងាច ហើយបានរួច។ ខ្ញុំក៏ចាំមិនបានថាពេលវេលាយូរប៉ុនណា ដឹងថាបានធ្វើ ចាក់ទាល់តែពេញត្រចៀកស្ពានទី១ហ្នឹងបាទ។

[១០:៥៦:២៥]

**ស៖** តើក្នុងចន្លោះពេលហ្នឹងមានអ្នកដែលបំពេញការងារអត់ទាន់ដែរឬទេ អត់ទាន់បានផែនការ ៥ម៉ែត្រគូប ក្នុងមួយថ្ងៃហ្នឹងទេ?

**ឆ៖** អ្នកដែលបំពេញការងារមិនពេញក្នុង៥ម៉ែត្រគូបនោះគឺ ខ្ញុំភ្លេចដែរ ប៉ុន្តែច្រើនជាស្ត្រី នារី។

**ស៖** មានអ្វីកើតឡើងចំពោះពួកគេនៅពេលដែលមិនបានបំពេញការងារតាមផែនការកំណត់?

**ឆ៖** ខ្ញុំមិនបានដឹងទេ ព្រោះកងខុសគ្នាបាទ។ កងខ្ញុំគឺអត់មាន សុទ្ធតែពេញផែនការបាទ។

**ស៖** ជាមួយគ្នានេះដែរ លោកលើកឡើងជូនអង្គសវនាការមុននេះថា ការងារនេះលោកធ្វើ ធ្វើដោយសារខ្លាច។ តើលោកខ្លាចអ្វី?

**ឆ៖** ការខ្លាចនេះ ខ្លាចគេយកទៅសម្លាប់ចោលតែម្តង។ ខ្លាចវិន័យរបស់ទិស របស់អង្គការ។

**ស៖** ធ្លាប់ឃើញ ធ្លាប់មានអ្វីដែលលោកឃើញផ្ទាល់ភ្នែកទេ ដែលនាំឲ្យលោកខ្លាចអ៊ីចឹង?

**ឆ៖** គឺខ្ញុំអត់បានច្បាស់ទេ ឮតែតាមអង្គការគេថា កង់ប្រវត្តិសាស្ត្រ ដូចថាយើងវិលមិនទាន់គេពេលប្រជុំហ្នឹង គេចេះតែអប់រំអំពីគោរពវិន័យអង្គការចាត់តាំង ប្តេជ្ញាចិត្ត ខ្លាចតាមគេនិយាយបាទ។

**ស៖** នៅការដ្ឋានដែលលោកបំពេញការងារហ្នឹង លោកដែលឃើញមានគេដាក់ទណ្ឌកម្មមនុស្សនៅចំពោះមុខទេ?

**ឆ៖** ខ្ញុំមិនបានឃើញទេ បាទ។

**ស៖** ក្នុងកាលៈទេសៈដែលលោកបំពេញការងារពិសេស ៥ម៉ែត្រគូប ក្នុងមួយថ្ងៃហ្នឹង លោក

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

មានម៉ោងបន្ថែមពេលយប់ទេ?

[១០:៥៩:២៥]

**ឆ៖** លក្ខណៈពិសេសនោះ ដឹងតែក្រោកពីម៉ោងបី ម៉ោងបួនព្រឹកហ្នឹង ទល់ម៉ោងប្រាំបានរួច អត់មានពេលសម្រាកទេ ហូបបាយក្នុងអន្លង់ដី។

**ស៖** ក្រៅពីការងារលើកទំនប់នេះ លោកមានការងារបន្ថែមអ្វីផ្សេងទៀតនៅក្នុងអំឡុងពេលដែលលោកនៅអាងត្រពាំងថ្មហ្នឹងទេ?

**ឆ៖** ក្រោយពីចាក់ស្ពានពេញ ខ្ញុំគេឱ្យនៅធ្វើស្រែប្រាំងនៅនោះ នៅត្រពាំងថ្ម។

**ស៖** បានន័យថាលោកបញ្ចប់ការងារនៅការដ្ឋានរែកដីហ្នឹងហើយ បានទៅធ្វើការងារមួយទៀត ប៉ុន្តែអ្វីដែលខ្ញុំចង់សួរ គឺចង់សួរថា ទន្ទឹមនឹងពេលដែលលោករែកដីហ្នឹង លោកឆ្លើយអំមិញអត់មានការងារពេលយប់ទេ។ តើលោកមានការងារបន្ថែមផ្សេងទៀតទេ ក្រៅពីរែកដីហ្នឹង ក្នុងអំឡុងពេលតែមួយហ្នឹង?

**ឆ៖** អត់មានទេ ព្រោះនេះដល់ម៉ោងបួន ម៉ោងប្រាំ ដល់ពេលសម្រាក។ គ្មានការងារផ្សេងទេ។

**ស៖** មុននេះផងដែរ លោកលើកឡើងថា លោកបានហូបរបបអាហារហ្នឹង មិនគ្រប់គ្រាន់ទេ អីចឹងហើយលួចលាក់ទៅចុះប្លុង។ ខ្ញុំចង់សួរលោកបញ្ជាក់ថា តើការដែលលោកទៅចុះប្លុងហ្នឹង ទៅដកមើមយកមកហូបហ្នឹង លោកធ្វើដោយចំហ បានន័យថា គេអនុញ្ញាតឱ្យគ្រប់គ្នាធ្វើអីចឹង ឬក៏យ៉ាងម៉េចវិញ?

**ឆ៖** ការទៅដឹកប្លុងនោះ មិនអាចចំហបានទេ។ ទាល់តែលួចលាក់ បាទ។

**ស៖** ចុះធ្លាប់មាន ធ្លាប់បាន ត្រូវបានគេតាមទាន់ ឬក៏ធ្លាប់បានឃើញអ្នកណាដែលគេតាមទាន់ពេលទៅលួចហ្នឹងទេ?

**ឆ៖** ចុះប្លុងនោះ គឺនៅតាមស្រែមិនចាំបាច់លួចទេ។ លួចតែពេលវេលាឆ្លៀត ពេលវេលាមួយម៉ោងអីប៉ុណ្ណោះ។

[១១:០២:៣៩]

**ស៖** សូមលោកជួយបញ្ជាក់កន្លែងនេះឱ្យច្បាស់បន្តិច។ បានន័យថា លោកថាទៅចុះប្លុងហ្នឹងអត់លួចទេ ប៉ុន្តែលួចពេលវេលា។ តើពេលវេលាហ្នឹង លោកលួចពីណា? បានន័យថា ក្នុងម៉ោងដែលលោកធ្វើការ ឬក៏ក្រោយម៉ោងដែលលោកសម្រាកហើយ បានលោកទៅ អីចឹងឬយ៉ាងណា?

**ឆ៖** ពេលវេលា គឺពេលវេលាចប់ម៉ែត្រគូបហើយ។ ដូចម៉ោងប្រាំ យើងអាចទៅផ្អៀតពេលប្អូនដប់នាទី កាប់ចុះប្តុង ចុះច្រើនដែរ។

**ស៖** អ៊ីចឹងបានន័យថា ពេលដែលលោកចេញពីកន្លែងសម្រាកទៅ ទៅចុះប្តុងហ្នឹង គឺមិនឲ្យគេដឹងទេ?

**ឆ៖** បាទ។

**លោក ស្រ៊ា រតនៈ៖**

សូមអរគុណលោកដើមបណ្តឹងរដ្ឋប្បវេណី។ លោកប្រធាន ខ្ញុំសូមការអនុញ្ញាតជូនវេទិកានេះបន្តទៅសហការីអន្តរជាតិរបស់ខ្ញុំ។

**ប្រធានអង្គជំនុំ៖**

អរគុណ។ សូមអញ្ជើញ!

**លោក ចូសេហ្វ អេនគ្រូ ប៊ីយលី៖**

សូមអរគុណលោកប្រធាន។

សូមជម្រាបសួរលោក លោកស្រីចៅក្រម សហការី ភាគីទាំងអស់។

[១១:០៤:០៨]

**សួរដោយលោក ចូសេហ្វ អេនគ្រូ ប៊ីយលី៖**

**ស៖** ជម្រាបសួរលោកសាក្សី ខ្ញុំមានសំណួរមួយចំនួនសួរទៅលោក។ នៅពេលដែលលោកធ្វើការនៅការដ្ឋានទំនប់ត្រពាំងថ្ម តើលោកដែលឮសួរគេចាត់ទុកកម្លាំងពលកម្មណាថា ខ្ជិលច្រអូសទេ?

**លោក ញឹប ហល់៖**

**ឆ៖** បាទ មិនច្បាស់សំណួរ។

**ស៖** តើលោកធ្លាប់ដែលឮសួរអ្នកណាម្នាក់ មេកងក្តី ឬក៏អ្នកណាម្នាក់ដែលមានតួនាទីចាត់ទុក ឬក៏និយាយថា ពលករណាខ្លះជាអ្នកដែលខ្ជិលច្រអូសមិនធ្វើការ ឬថា<មិនខំប្រឹងធ្វើការ>ទេ?

**ឆ៖** បាទ គឺពេលដែលប្រជុំ គេអប់រំថា និយាយ គឺថាគោរពអង្គការចាត់តាំងអត់មានអ្នកណាខ្ជិលបានទេ។ គឺពាក្យដែលថា ល្មួច ខ្ជិលអីអត់មាន អត់ដែលឮទេ។

**ស៖** នៅពេលលោកនៅការដ្ឋាននោះ តើលោកដែលឮមេកងហៅកងណាមួយថា "កងករណីពិសេស" ទេ?

**ផ៖** ខ្ញុំមិនដែលឮទេ "កងករណី" មិនដឹងជាកងអីទេ។

**ស៖** តើគេដែលឲ្យលោកសរសេរប្រវត្តិរូបទេ នៅពេលដែលលោកនៅឯការដ្ឋានលើកទំនប់នោះ?

**ផ៖** គេមិនដែលឲ្យខ្ញុំសរសេរអីទេ។ ខ្ញុំថាអត់ចេះៗ។

**ស៖** តើធ្លាប់មានអ្នកណាម្នាក់សួរអំពីប្រវត្តិរូបរបស់លោកទេ លោកមកពីណា ក្រុមគ្រួសារលោកធ្វើអ្វីដែរ ជាដើម។ល។ តើមានអ្នកដែលគេដែលសួរលោកទេ?

**ផ៖** គេមិនដែលសួរទេ ព្រោះអីយើងអត់ចេះ អត់ចេះនិយាយ។

**ស៖** <សូមទោស> ខ្ញុំ<មិនយល់>ចម្លើយ<របស់>លោក<>ទេ។ តាមខ្ញុំស្ដាប់ឮ គឺថាគេមិនដែលសួរលោកទេ ដោយសារថាលោកមិនចេះពន្យល់។ តើលោកចង់និយាយថាយ៉ាងដូចម្ដេច ដែលថាលោកមិនចេះពន្យល់ប្រវត្តិរូបខ្លួនឯងហ្នឹង?

[១១:០៨:០៧]

**ផ៖** គឺយើងមិនចេះនិយាយ គេសួរទៅ យើងថាអត់ដឹង គេមិនដែលមកសួរទេ។ សួរអីថា អត់ដឹង អត់ចេះ។

**ស៖** ដើម្បីបញ្ជាក់ឲ្យច្បាស់ គឺថាមានគេឲ្យលោក ប្រាប់គេអំពីប្រវត្តិរបស់លោក ប៉ុន្តែដោយសារថា លោកមិនចេះរៀបរាប់គេក៏ឈប់សួរទៅ អ៊ីចឹងមែនទេលោក?

**ផ៖** បាទ គឺខ្ញុំអត់ចេះ។

**ស៖** នៅពេលលោកនៅឯការដ្ឋានទំនប់ត្រពាំងថ្ម តើលោកមានដែលដឹងថាខ្លួនលោក ឬក៏សមាជិកនៅក្នុងកងរបស់លោកត្រូវបានបុគ្គលណាម្នាក់គេតាមដាន ឃ្លាំមើលដែរឬទេ?

**ផ៖** ពេលនោះ គឺខ្ញុំមិនសូវជាចាប់អារម្មណ៍អារឿងអ្នកតាមដានអីទេ ព្រឹកឡើង ល្ងាចឡើង ដឹងតែចូលដេកយកកម្លាំងប៉ុណ្ណោះ។ ខ្ញុំមិនដែលអង្គុយលេង និយាយជាមួយអ្នកណាទេ។

**ស៖** នៅពេលនោះ តើលោកមានដែលបានដឹងអ្នកណាម្នាក់ដែលជាអ្នករដ្ឋការ ឬក៏ទាហាននៃរបបលន់ នល់ ធ្វើការនៅការដ្ឋានទំនប់ត្រពាំងថ្មដែរទេ?

**ផ៖** ខ្ញុំអត់ដឹងផង អត់ដឹងទេ។

**ស៖** នៅក្នុងពេលណាមួយដែលលោកធ្វើការនៅការដ្ឋាននោះ តើលោកមានដឹង ចាប់អារម្មណ៍ដឹងថា មានកម្មាភិបាលមកពីភូមិភាគនិរតីមកដល់ការដ្ឋាននោះទេ?

**ឆ៖** ខាងនិរតីខ្ញុំមិនសូវជាស្គាល់គេទេ គេថានិរតី ក៏និរតីនឹងគេទៅ ប៉ុណ្ណោះឯង។

[១១:១១:៥៣]

**ស៖** តើលោកធ្លាប់ឃើញគេចាប់ខ្លួនអ្នកណាទេ<>នៅពេលដែលលោកនៅការដ្ឋាននោះ?

**ឆ៖** ខ្ញុំមិនដែលឃើញគេចាប់ខ្លួនទេ អត់។

**ស៖** តើលោកមានបានដឹងថា មានអ្នកណាម្នាក់នៅក្នុងកងរបស់លោកបាត់ខ្លួនដែរទេ?

**ឆ៖** ខ្ញុំអត់ដឹងទេ។ មិនបានដឹង។

**ស៖** នៅពេលដែលលោកលើកឡើងខាងដើមថា នៅក្នុងកិច្ចប្រជុំ គេនិយាយអំពីផែនការការងារជាមួយលោក។ អ្នកណាដែលនិយាយអំពីផែនការការងារជាមួយនៅក្នុងកិច្ចប្រជុំនោះ?

**ឆ៖** គឺពេលប្រជុំមេកងរយ គឺមេកងរយថាអង្គការថ្នាក់លើ មិនដឹងអង្គការថ្នាក់លើឯណា ផែនការរបស់ថ្នាក់លើ។ មេកងប្រហែលជាគាត់ថាតាមគេដែរ។ រកអង្គការឯណាឃើញ ជាផែនការ។

**ស៖** ចុះនៅក្នុងកិច្ចប្រជុំហ្នឹង តើផែនការការងារហ្នឹងវាមានអ្វីខ្លះ? តើផែនការការងារហ្នឹងមានព័ត៌មានអ្វីខ្លះដែរ <ដែលមេកងទទួលបានពីថ្នាក់លើទាក់ទងនឹងផែនការហ្នឹង>?

**ឆ៖** ផែនការការងារ ព័ត៌មានៗផែនការលើកទំនប់ ដឹងតែលើកទំនប់ហ្នឹងឯង ព័ត៌មានផ្សេងអត់មាន គឺទិសរបស់អង្គការ។

**ស៖** តើគេដែលប្រាប់លោកថា ទំនប់ហ្នឹងត្រូវតែធ្វើឱ្យចប់សព្វគ្រប់នៅថ្ងៃណា ខែណា ឆ្នាំណាដែរទេ?

**ឆ៖** ខ្ញុំអត់ដឹង គេឱ្យទៅលើក គឺលើកដាក់ស្ពានរួច ក៏គេឱ្យឈប់ ក៏ឈប់។ អត់ដឹង។

**ស៖** តើលោកដែលឮសួរថាការដ្ឋានទំនប់ត្រពាំងថ្មនេះ ចាត់ទុកជាសមរភូមិក្តៅដែរទេ?

**ឆ៖** ខ្ញុំអត់ដឹងផង។ គេឱ្យមកលើក លើកទៅ មិនដឹងជាសមរភូមិក្តៅត្រជាក់ អត់ដឹងទេ។

**ស៖** សូមអរគុណលោកដើមបណ្តឹងរដ្ឋប្បវេណី។

**លោក ចូសេហ្វ អេនគ្រូ ប៊ិយលី៖**

លោកប្រធាន ខ្ញុំអស់សំណួរហើយ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

សូមអរគុណលោកប្រធាន។

[១១:១៦:១០]

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** ជម្រាបសួរលោកសាក្សី! ខ្ញុំមានសំណួរមួយចំនួនតូចដើម្បីសួរបន្ត។ កាលពីព្រឹកមិញនេះ លោកបានឆ្លើយថាមុនពេលទៅទំនប់ត្រពាំងថ្ម លោកធ្លាក់ខ្លួនឈឺជាទម្ងន់ គឺនៅពេលដែលលោកធ្វើការនៅក្នុងកងចល័ត ហើយគេឲ្យលោកទៅច្រូតស្រូវ។ ដូច្នេះ <បើ>ខ្ញុំយល់<ត្រឹមត្រូវអ្វីដែលលោកនិយាយកាលពីព្រឹកមិញនេះ គឺ>ថាលោកចេញទៅធ្វើការនៅទំនប់ហ្នឹងគឺខែមិថុនា ឆ្នាំ១៩៧៧ មែនទេ? ពេលហ្នឹងហើយដែលលោក<>ទៅធ្វើការនៅទំនប់នោះ។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន គ្រាន់តែជាការកត់សម្គាល់ទេ។<ខ្ញុំគិតថា លោកចៅក្រម ឡាវ៉ែន៍ និយាយភ្លេចគិតត្រង់គាត់ប្រើឃ្លា "សួស្តីលោក>សាក្សី" តាមការពិតមិនមែនជាសាក្សីទេ។ <គាត់គួរប្រើឃ្លា "សួស្តីលោកដើមបណ្តឹងរដ្ឋប្បវេណីវិញ"។>

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកមេធាវី កូប៉េ ដែលបាននិយាយអំពីកំហុសអចេតនារបស់ខ្ញុំនេះ។ ឥឡូវនេះ ខ្ញុំត្រឡប់មកសំណួររបស់ខ្ញុំវិញ ព្រោះចំណុចហ្នឹងវាមិនសំខាន់ទេ។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** លោកដើមបណ្តឹងរដ្ឋប្បវេណី តើលោកអាចបញ្ជាក់បានទេថា គេបញ្ជូនឲ្យលោកទៅធ្វើការនៅទំនប់ត្រពាំងថ្មហ្នឹង គឺខែមិថុនា ឆ្នាំ១៩៧៧ មែនទេ?

**លោក ញឹប ហល់៖**

**ឆ៖** បាទ១ ឆ្នាំ។

**ស៖** ឥឡូវនេះ ខ្ញុំនិយាយអំពីជំងឺរបស់លោក ហើយនិងការសម្រាកពេទ្យ។ ខ្ញុំចង់ដឹងថា លោកឈឺហ្នឹង ឈឺមុនពេលគេបញ្ជូនលោកទៅត្រពាំងថ្មតែបន្តិចទេ ឬក៏យូរដែរទេ បានឈឺហើយបានគេបញ្ជូនទៅនោះ?

**ឆ៖** ឈឺយូរហើយដែរ បាទ ជាប្រហែលជាបួន ប្រាំ ប្រាំមួយខែហើយ។ ជាបានបួន ប្រាំ ប្រាំមួយខែ។

[១១:១៨:៥០]

**ស៖** បាទ សូមអរគុណ។ ដូច្នេះ នៅពេលដែលលោកឈឺ គឺគេឲ្យលោកច្រូតស្រូវ ហើយលោកលីបាវស្រូវ។ តើអ៊ីចឹងមែនដែរទេ?

**ឆ៖** បាទ ពេលថ្ងៃច្រូតស្រូវ ពេលយប់លីបាវស្រូវ បាទ។

**ប្រធានអង្គជំនុំ៖**

យ៉ាងម៉េចទៅលោកមេធាវី គង់ សំអុន?

**លោក គង់ សំអុន៖**

លោកប្រធាន ខ្ញុំស្តាប់សំណួរតាមរយៈការបកប្រែរបស់លោកចៅក្រមអម្បាញ់មិញនេះ អត់ច្បាស់ជាភាសាខ្មែរ ដោយឮថាពេលឈឺឲ្យទៅច្រូតស្រូវ និងលីបាវស្រូវ ក៏ប៉ុន្តែតាមសក្ខីកម្មរបស់សាក្សីពីខាងដើមថា គាត់ឈឺដោយសារតែពេលថ្ងៃហ្នឹងច្រូតស្រូវ ហើយពេលយប់លីបាវស្រូវ។ អ៊ីចឹង ខ្ញុំចង់បញ្ជាក់ថា តើសំណួរយ៉ាងម៉េច? បាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ហើយតាំងសំណួរសាជាថ្មីម្តងទៀតឲ្យច្បាស់លាស់!

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** លោកដើមបណ្តឹងរដ្ឋប្បវេណី កាលពីព្រឹកមិញនេះ លោកឆ្លើយថាលោកបានសម្រាកពេទ្យ គឺមានក្អកផ្តាក់ឈាម ដូច្នេះប្រសិនបើខ្ញុំស្តាប់មិនច្រឡំទេ គឺថាលោកឈឺហ្នឹង គឺនៅពេលដែលលោកកំពុងតែច្រូតស្រូវ ហើយនិងលីបាវស្រូវ។ តើនេះជាចម្លើយរបស់លោកដែលបានឆ្លើយកាលពីព្រឹកមិញហ្នឹងមែនទេ?

**លោក ញឹប ហល់៖**

**ឆ៖** បាទ គឺជាចម្លើយដែលខ្ញុំបានឆ្លើយនៅព្រឹកមិញហ្នឹងឯង។

**ស៖** វាដូចទៅនឹងអ្វីដែលខ្ញុំបានស្តាប់យល់អ៊ីចឹងដែរ។ ឥឡូវនេះយើងច្បាស់ទាំងអស់គ្នាហើយ។ <លោកប្រាប់ថា កាលនោះ លោកធ្វើការហត់ខ្លាំងណាស់។> តើលោកអាចបញ្ជាក់បានទេ នៅសម័យនោះលោកមានអាហារហូបចុកគ្រប់គ្រាន់ទេ?

**ឆ៖** សម័យនោះ នៅមានបាយហូបខ្លះពេលដែលកំពុងច្រូតគឺមាន តែអស់ស្រូវច្រូតហើយអស់បាយស៊ី គឺហូបបបរហើយ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** <នៅក្នុងជំនាន់នោះ>តើលោក និងអ្នកធ្វើការដទៃទៀតខ្វះខាតអាហារហូបចុកទេ ឬក៏លោកបានហូបចុកបានគ្រប់គ្រាន់?

**ឆ៖** នៅពេលនោះ គឺហូបចុកអត់គ្រប់គ្រាន់ទេ។ គ្រាន់តែមានរបប បាយនៅពេលច្រូតកាត់ផុតច្រូតកាត់ទៅអត់ អស់របបហើយ បាទ មានតែរបបបបរវិញ។

**ស៖** ពេលដែលគេឲ្យលោកលីបាវស្រូវដើម្បីដាក់រទេះហ្នឹង តើគេមានប្រាប់ថាតើបាវស្រូវហ្នឹងគេដឹងយកទៅណាទេ?

[១១:២៣:៥៤]

**ឆ៖** ខ្ញុំអត់ដឹងទេ គ្រាន់តែលីដាក់ប៉ារ៉ុងពេញទៅ មិនដឹងគេទៅណា ប៉ារ៉ុងរទេះភ្លើងនោះ មិនដឹងគេយកទៅណាទេ អត់ដឹង។

**ស៖** នៅៗពេលនោះ គឺលោកឃើញ<>មានរទេះភ្លើងហ្នឹងដឹក<ស្រូវ>ចូលមក<កន្លែងដែលលោកធ្វើការហ្នឹងដែរ>ទេ? ឬក៏ឃើញតែដឹងចេញទៅទេ?

**ឆ៖** អត់មានដឹកចូលទេ មានតែដឹកចេញ បើដឹកៗតែអំបិលមក។

**ស៖** លោកឆ្លើយថា "មានគេដឹងអំបិលចូលមកតំបន់ដែលលោកធ្វើការ"។ អំបិលហ្នឹងគេដឹកយកមកពីណាដែរ លោកដឹងទេ?

**ឆ៖** ខ្ញុំអត់ដឹងទេ ដឹងតែគេឲ្យទៅដាក់អំបិលទៅ ដាក់មក មិនដឹងគេដឹកមកពីណាទេ។ ដាក់អំបិលរួច គឺដាក់ស្រូវទៅវិញ ប៉ុណ្ណោះឯង។

**ស៖** គេឲ្យលោកលីបាវស្រូវដាក់ក្នុងទូរថភ្លើងហ្នឹងរយៈពេលប៉ុន្មានខែដែរ?

**ឆ៖** លីមួយអស់ស្រូវ បាទ នៅរោងម៉ាស៊ីនព្រហ្វិតហ្នឹង គឺមួយអស់ស្រូវ ទាល់អស់ស្រូវទៅ គេឈប់ឲ្យលី។ ប្រមូលពីគ្រប់ស្រុកក្នុងតំបន់៥មក ប្រមូលដាក់ប៉ារ៉ុងរទេះភ្លើង មិនដឹងគេដឹកទៅណាទេ។

**ស៖** ដូច្នេះឃ្លាំងស្រូវហ្នឹង គឺគេប្រមូលស្រូវពីគ្រប់កន្លែងទាំងអស់នៃតំបន់៥ ហើយបានដឹកទៅដាក់ទូរថភ្លើង។ អ៊ីចឹងខ្ញុំចឹងដឹងថា លោកធ្វើការដឹក លីបាវស្រូវហ្នឹង<រយៈពេលយូរប៉ុន្មាន>ដែរ? <មួយថ្ងៃ ពីរថ្ងៃ ឬបីថ្ងៃ?>

**ឆ៖** ខ្ញុំមិនចាំទេ គ្រាន់តែថាដល់ពេលគេត្រូវការ គេទៅយកចល័តមកលី បាទ កងខ្ញុំ។ មិនដឹងប៉ុន្មានខែ ប៉ុន្មានថ្ងៃទេ អត់ចាំបាន។

**ស៖** តើមានរទេះភ្លើងហ្នឹងមួយ ឬក៏ច្រើន?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** តែក្បាលរទេះភ្លើង ខ្ញុំមិនដែលបានឃើញៗតែទូរទេះភ្លើងប៉ុណ្ណោះឯង ឲ្យដាក់ មិនដឹងក្បាលនៅឯណាផង។

**ស៖** ប្រហែលជាមានបញ្ហាបកប្រែក៏មិនដឹង។ ខ្ញុំចង់ដឹងថារទេះភ្លើងហ្នឹង មកហ្នឹង មកដឹកហ្នឹងតែម្តងទេ ឬក៏មកច្រើនដង ទៅមកៗ?

**ឆ៖** មិនមែនតែម្តងទេ ច្រើនដង ប៉ុន្តែវាមិនចាំពេលវេលា ចាំដង ចាំជើង អត់ចាំ។

[១១:២៨:៣៣]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ខ្ញុំគិតថាឥឡូវនេះគឺដល់ម៉ោងហើយ អ៊ីចឹងខ្ញុំសូមបញ្ចប់ត្រឹមហ្នឹង។

សូមអរគុណលោកដើមបណ្តឹងរដ្ឋប្បវេណី។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

ឥឡូវនេះដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយកន្លះរសៀលនេះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញ ដល់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ នៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់ ព្រមទាំងបុគ្គលិកអង្គការ ធី.ភី.អូ មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះ នៅរសៀលនេះ វេលាម៉ោងមួយកន្លះនៅរសៀលនេះ។ ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ទៅកាន់បន្ទប់រង់ចាំខាងក្រោមសវនាការនេះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះនៅរសៀលនេះ ឲ្យបានមុនម៉ោងមួយកន្លះ។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១១:២៩ នាទី ដល់ម៉ោង ១៣:២៨ នាទី)*

[១៣:២៨:៤៤]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសកិច្ចដំណើរការសវនាការ ហើយតទៅនេះផ្តល់វេទិកាជូនទៅក្រុមមេធាវី

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ការពារក្តី ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ហើយដំបូងនេះផ្តល់វេទិកាជូនទៅសហមេធាវីការពារក្តីលោក នួន ជា។

**លោក វ៉ិចទ័រ កូប៉េះ៖**

សូមអរគុណលោកប្រធាន ជម្រាបសួរលោក លោកស្រីចៅក្រម។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក វ៉ិចទ័រ កូប៉េះ៖**

**ស៖** ជម្រាបសួរលោកដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំមិនមានសំណួរច្រើនប៉ុន្មានទេសម្រាប់រសៀលនេះ មានតិចតួចទេ។ ខ្ញុំសូមសួរលោក តាមខ្ញុំយល់មិនច្រឡំទេ នៅពេលលោកធ្វើការនៅការដ្ឋានទំនប់ត្រពាំងថ្ម ខ្លួនលោកផ្ទាល់ហ្នឹង គឺថាមិនធ្លាប់ដែលធ្លាក់ខ្លួនឈឺទេ តើត្រឹមត្រូវដែរឬអត់ទេ?

**លោក ញឹប ហល់៖**

**ឆ៖** បាទ ត្រឹមត្រូវ។

[១៣:៣០:២៦]

**ស៖** ហើយបើខ្ញុំយល់មិនច្រឡំដែរនោះ គឺថានៅពេលដែលលោកធ្វើការនៅការដ្ឋានទំនប់ត្រពាំងថ្ម ខ្លួនលោកហ្នឹង គឺមិនធ្លាប់ត្រូវបានមេរបស់លោកហ្នឹងដាក់ទណ្ឌកម្ម<វិន័យ>ទេ។ អ៊ីចឹងមែនទេ?

**ឆ៖** បាទ ត្រឹមត្រូវ។

**ស៖** ហើយបើខ្ញុំយល់មិនច្រឡំដែរនោះ នៅពេលដែលនៅឯការដ្ឋានទំនប់ត្រពាំងថ្ម លោកមិនធ្លាប់បានទទួលរងគ្រោះដោយសារគ្រោះថ្នាក់ការងារនោះទេ មែនទេ?

**ឆ៖** បាទ មិនដែល។

**ស៖** លោកដើមបណ្តឹងរដ្ឋប្បវេណី បើតាមខ្ញុំយល់នៅពេលលោកធ្វើការនៅការដ្ឋានទំនប់ត្រពាំងថ្ម លោកមិនធ្លាប់ដែលត្រូវបានគេវាយដំ ឬក៏ធ្វើទារុណកម្មលើរូបរាងកាយក្នុងរូបភាពណាមួយទេ។ អ៊ីចឹងមែន ឬក៏អត់ទេ?

**ឆ៖** មិនមានទេ ក៏ប៉ុន្តែទទួលការចាត់តាំង បាទ ត្រូវតែធ្វើ។

[១៣:៣២:១៦]

**ស៖** បាទ ខ្ញុំយល់ហើយ លោកដើមបណ្តឹងរដ្ឋប្បវេណី ហើយ<ជាចុងក្រោយ>បើខ្ញុំយល់មិនច្រឡំដែលនោះ នៅពេលលោកធ្វើការនៅការដ្ឋានទំនប់ត្រពាំងថ្ម លោកមិនធ្លាប់បានឃើញការប្រព្រឹត្ត

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ឃោរឃៅ ឬក៏ការសម្លាប់<អ្នករួមការងារជាមួយ>លោកទេ មែនទេ?

**ឆ៖** បាទ មិនដែលឃើញ។

**ស៖** លោកដើមបណ្តឹងរដ្ឋប្បវេណី តើលោកមានទទួលរងគ្រោះនៅពេលនៅការដ្ឋានទំនប់ត្រពាំងថ្ម <ដូចជា>មានការបាត់បង់សម្ភារៈផ្ទាល់ខ្លួន <ឬប្រាក់ចំណូល>ណាមួយទេ?

**ឆ៖** ព្រោះវាអត់ដែលមានអីជាប់នឹងខ្លួន អត់មានកម្មសិទ្ធិ។

**ស៖** បាទ ត្រឹមត្រូវហើយ។ <លោកដើមបណ្តឹងរដ្ឋប្បវេណី>តើសព្វថ្ងៃនេះ តើលោកមានទទួលការប៉ះពាល់ទន្ទិចផ្លូវចិត្ត ការធុញថប់អារម្មណ៍ ឬជំងឺបាក់ស្បាត ជំងឺបាក់ស្មារតីណាមួយ ដោយសារតែការងារនៅការដ្ឋានទំនប់ត្រពាំងថ្មនោះដែរ ឬទេ?

**ឆ៖** ជាមាន មាននូវការបាក់កម្លាំង មានការឃើញរបស់ធ្ងន់ៗដូចខ្លាច ប៉ុណ្ណឹង។

**ស៖** តើ<>ថ្មីៗនេះ លោកមានបានទៅជួបគ្រូពេទ្យខាងផ្នែករោគសាស្ត្រ ចិត្តសាស្ត្រនេះដែរទេ?

**ឆ៖** មិនដែលបានទៅជួប។

**ស៖** តើធ្វើដូចម្តេចទើបលោកដឹងថា លោកនេះទទួលរងការឈឺចាប់ដោយសារតែជំងឺបាក់ស្បាត?

**ឆ៖** ព្រោះមិនដឹងទៅសួរនរណាៗ ពិបាកៗតែឯងទៅ។

**ស៖** ខ្ញុំយល់ហើយលោក។ ប៉ុន្តែលោកអាចជម្រាបជូនអង្គជំនុំជម្រះថា ការឈឺចាប់របស់លោកហ្នឹងគឺវាបណ្តាលមកពីការងារ<ច្រើនខែ>នៅឯការដ្ឋាននោះ ឬក៏ជំងឺនេះវាបណ្តាលដោយសារតែជំងឺរបស់លោក<ប្រាំមួយខែមុន> ឬក៏ដោយសារជំងឺនេះវាពាក់ព័ន្ធទៅនឹងសាច់ញាតិរបស់លោកដូចជាបងប្អូន ឪពុកម្តាយ ឬក៏ដោយសារតែលក្ខខណ្ឌការងារនៅឯការដ្ឋាននោះ? <តើលោកអាចនិយាយភ្ជាប់រវាងការងារនៅការដ្ឋានទំនប់នោះ ជាមួយនឹងស្ថានភាពរបស់លោកនាពេលបច្ចុប្បន្នបានទេ?>

[១៣:៣៦:៤២]

**ឆ៖** ការឈឺ គឺជាលក្ខខណ្ឌនៅការដ្ឋានដែលខ្ញុំធ្លាប់ជួបប្រទះ។

**ស៖** ខ្ញុំ ឥឡូវនេះកំពុងតែពិនិត្យមើលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់លោក។ ខ្ញុំតាមរយៈទម្រង់នេះ ខ្ញុំដឹងថាលោកនេះបានបំពេញទម្រង់នេះដោយខ្លួនឯង។ <លោកប្រធាន> ទម្រង់នៃពាក្យសុំនេះគឺឯកសារ <E3/5018>, ERN <>ខ្មែរ 00560150, បារាំង 00897059 ហើយអង់គ្លេស 01060039 ដែលលោកបាននិយាយថា លោកបាត់បង់បងប្អូនពីរនាក់ ឪពុក <បងម្នាក់

និង>ក្លួយ<ប្រុសម្នាក់> លោករៀបរាប់អំពីការបាត់បង់ទ្រព្យសម្បត្តិ។ ប៉ុន្តែក្នុងពាក្យសុំនេះលោកមិនបាននិយាយថា លោកបានកើតមានជំងឺបាក់ស្បាតនេះដោយសារតែការងារនៅទំនប់ត្រពាំងថ្ម<ទេ>។ លោកមានហេតុផលអីទេ បញ្ជាក់ថា ហេតុអីក៏លោកមិនពន្យល់ថា វាមានជាប់ព័ន្ធនឹងការងារនោះ?

**ប្រធានអង្គជំនុំ៖**

ដើមបណ្តឹងរដ្ឋប្បវេណីកុំអាលទាន់ឆ្លើយតប!

អញ្ជើញសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក ចូសេហ្វ អេនឌ្រូ ប៊ីយលី៖**

បាទ ដើម្បីជាប្រតិចារឹកលោកប្រធាន។ នៅខាងក្រោមផ្នែកដែលមេធាវីការពារក្តីទើបតែលើកឡើងមកឲ្យដើមបណ្តឹងរដ្ឋប្បវេណីស្តាប់ឡើងវិញ គឺ<មានបន្ទាត់មួយត្រង់>លេខប្រាំមួយ<ដែលលោកមេធាវីមិនបាននិយាយ មានសរសេរ>ថា "ខ្ញុំធ្វើការធូន់ធូរហួសកម្លាំងពេករហូតដល់ខ្ញុំធ្លាក់ខ្លួនចុះខ្សោយ<ខ្លាំង">។ <ខ្ញុំសូមឲ្យការកត់សម្គាល់នេះបំពេញនៅក្នុងកំណត់ត្រាប្រតិចារឹកផង។>

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ខ្ញុំសូមសួរសំណួរ។ ខ្ញុំបានស្តាប់មួយរយៈគឺថា មេធាវីការពារក្តីលោកហាក់បីដូចជាលើកឡើងវិញអំពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ មានសេចក្តីសម្រេចពាក់ព័ន្ធទៅនឹងការទទួលយក<តាំងពីសវនាការបឋម។> បើសិនណាជាលោកចង់ដឹង<មូលហេតុ ដែលគេ> ទទួលយក <លោកអាចត្រឡប់ទៅមើលសេចក្តីសម្រេចវិញបាន។ លើសពីនេះ តើមានអ្វីពាក់ព័ន្ធគ្នាក្នុងការតាំងសំណួរទាំងនេះ? គឺសំណួរទាក់ទងនឹង> ការឈឺចាប់<ផ្ទាល់ខ្លួនរបស់គាត់?>

**លោក វ៉ិចទ័រ កូប៉េ៖**

ភាពពាក់ព័ន្ធនៅក្នុងវិធាន<ផ្ទៃក្នុង គឺវិធាន>២៣ ស្ទួនបួន <គឺខ្ញុំបកស្រាយថា "នៅពេលដែលអង្គជំនុំជម្រះរកឃើញអំពីពិរុទ្ធភាពរបស់ជនជាប់ចោទ អង្គជំនុំជម្រះអាចសម្រេចផ្តល់ឲ្យតែសំណងផ្លូវចិត្ត និងជាសមូហភាពទៅដល់ភាគីដើមបណ្តឹងរដ្ឋប្បវេណីតែប៉ុណ្ណោះ។ តាមគោលបំណងនៃវិធានទាំងនេះ សំណងផ្លូវចិត្ត និងសំណងសមូហភាព គឺជាវិធានទាំងឡាយដែល ទទួលស្គាល់នូវការខូចខាតដែលដើមបណ្តឹងរដ្ឋប្បវេណីទទួលដោយសារការប្រព្រឹត្តនូវបទឧក្រិដ្ឋរបស់ជនជាប់ចោទ ដែលត្រូវបានផ្តន្ទាទោស"។ បើទោះណាជា នួន ជា ត្រូវបានផ្តន្ទាទោសនូវអ្វីដែលបានប្រព្រឹត្តនៅអាងត្រពាំងថ្មក៏ដោយ គឺថា <អ្វីដែលបានកើតឡើងចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ដែលគាត់>បានសម្រាក<នៅ>មន្ទីរ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ពេទ្យប្រាំមួយខែ<មុនពេលហេតុការណ៍កើតឡើង ជាពេលដែលគាត់ (នួន ជា) មិនត្រូវផ្តន្ទាទោស> ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

<ប៉ុន្តែ សេចក្តីសម្រេចថាតើ>ដើមបណ្តឹងរដ្ឋប្បវេណីនេះ <ពិត ឬមិនពិត គឺត្រូវបានសម្រេចរួចទៅហើយ នៅក្នុងសវនាការបឋមឯណោះ។ យើងមិនអាចលើកមកនិយាយនៅទីនេះបានទេ។ មើលទៅ លោកមេធាវីកំពុងព្យាយាមលើករឿងនេះមកនិយាយ។>

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ លោកស្រីចៅក្រម គាត់គឺជាដើមបណ្តឹងរដ្ឋប្បវេណីដែរក្នុងចំណោមដើមបណ្តឹងរដ្ឋប្បវេណី ៤០០០នាក់។ តើៗហេតុអ្វីក៏ នេះជាពេលដែលយើងអាចជំទាស់តវ៉ា អ្វីដែលសរសេរនៅក្នុងពាក្យសុំជាដើមបណ្តឹងរដ្ឋប្បវេណី <ឬការទទួលយកជាដើមបណ្តឹង? នេះជាពេលវេលាតែមួយដែលយើងអាចធ្វើ>។ ការទទួលរងការឈឺចាប់នេះ បើមិនទទួលមកពីការដ្ឋានទំនប់ត្រពាំងថ្មទេវាគ្មានន័យអ្វីទេ។

[១៣:៤១:១១]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ប្រហែលជាមានការយល់ច្រឡំ<អំពីកិច្ចដំណើរការនេះហើយ។ គេសម្រេចរួចហើយ។> ការទទួលយកពាក្យសុំនេះគឺ<ត្រូវ>បានទទួលយក<ជាស្ថាពរ>តាំងពី<សវនាការបឋម ដោយមានលទ្ធភាពនៃការប្តឹងឧទ្ធរណ៍ជាច្រើនផងដែរ។ល។> ឥឡូវនេះ គេបានបញ្ចូល<គាត់ជា>ជា<>ក្រុមរួមមួយហើយ។ <ដូច្នេះ ការបើកឡើងវិញអំពីកិច្ចដំណើរការទទួលយក ឬអំពីសេចក្តីសម្រេចអីជាដើម គឺមិនប្រព្រឹត្តទៅនៅក្នុងវគ្គនៃសវនាការនេះទេ, មិនមែនក្រោមវិធានផ្ទៃក្នុងទាំងនេះទេ>។

**លោក វ៉ិចទ័រ កូប៉េ៖**

ដូច្នេះ យើងខ្ញុំមិនមានលទ្ធភាពស្វែងយល់ ចង់ដឹងថាតើព្យសនកម្មរបស់គាត់នេះ ត្រូវស្វែងរកឲ្យឃើញថា បណ្តាលមកពីការងារនៅការដ្ឋានត្រពាំងថ្មដោយផ្ទាល់ឬក៏អត់<ទេ?> យោងទៅតាមវិធាន <> ២៣ ស្ទួនបួននេះ គឺត្រូវតែមេធាវីការពារក្តីត្រូវស្វែងរកឲ្យឃើញ ថាព្យសនកម្មនេះ បណ្តាលមកពីលក្ខខណ្ឌការងារនោះឬក៏យ៉ាងណា។ <យើងមិនមែនតវ៉ារឿងទទួលយក ឬមិនទទួលយកឯណា។ ខ្ញុំដឹង ថាគាត់នៅក្នុងក្រុមហ្នឹងមែន។> បើទោះណាជាអង្គជំនុំជម្រះផ្តល់នូវសំណងជំងឺចិត្តទៅដល់គាត់ ឬក៏មិនដល់ គឺត្រូវតែស្វែង ក៏ត្រូវតែស្វែងរកឲ្យឃើញថា វាពាក់ព័ន្ធមកពីការដ្ឋានទំនប់ត្រពាំងថ្ម ឬក៏អត់ដែរ។ <ហើយនេះជាអ្វីដែលខ្ញុំគិតថា ជាសវនាការបើកចំហរ។>

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[១៣:៤២:១៧]

**ប្រធានអង្គជំនុំ៖**

អញ្ជើញ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ អម្បាញ់មិញនេះ ខ្ញុំអង្គុយវិញដោយសារខ្ញុំឃើញលោកចៅក្រម ឡាវែន៍ គាត់ចង់និយាយដែរ។ ខ្ញុំគិតថាប្រហែលជាមានការយល់ច្រឡំធ្ងន់ធ្ងរណាស់ ចំពោះមេធាវីការពារក្តីនោះ<។ ជាក់ស្តែង នៅពេលសម្រាកអាហារថ្ងៃត្រង់ លោកមេធាវីបានរកមើលនៅក្នុង>វិធានផ្ទៃក្នុង <ហើយប្រហែលជាគាត់មិនទាន់យល់វិធានទាំងអស់ ឬក៏មិនអាចប្រើប្រាស់ព័ត៌មានទាំងហ្នឹងតាមមើល៍>។ <វាចាំបាច់ណាស់ដែល>គាត់ត្រូវតែយល់ថាដើមបណ្តឹងរដ្ឋប្បវេណីមិនចូលរួមក្នុងនីតិវិធីក្នុងនាមជាបុគ្គលឯកជនទេ គាត់ចូលរួមក្នុងនាមជាក្រុមរួមមួយ ហើយសំណង គឺត្រូវតែផ្តល់ជូនទៅក្រុមដើមបណ្តឹងរដ្ឋប្បវេណី មិនមែនផ្តល់ទៅបុគ្គលជាឯកជនទេ។ ដូច្នេះខ្ញុំគិតថា មេធាវីការពារក្តីត្រូវតែមើលសេចក្តីសម្រេចឡើយវិញ មើលសាលក្រមឡើងវិញ ពីព្រោះថានៅក្នុងសាលក្រមមានចែងច្បាស់ហើយអំពីចំណុចនេះ។ មេធាវីការពារក្តីអាចមានលទ្ធភាពប្តឹងឧទ្ធរណ៍បានអំពីការសម្រេចនៃការទទួលយកដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងពេលស៊ើបអង្កេត ហើយគឺតាំងពី២០១០ ឯណោះ ហើយតាំងពីឆ្នាំ២០១០នោះមេធាវីការពារក្តី នួន ជា, អៀង សារី, ខៀវ សំផន, អៀង ធីរិទ្ធិ នោះ គាត់មិនបានប្តឹងឧទ្ធរណ៍អំពីការសម្រេចអំពីការទទួលយកជាដើមបណ្តឹងរដ្ឋប្បវេណីទេ។ ដូច្នេះ ខ្ញុំសូមរំឭកអំពីវិធានជាមូលដ្ឋានរបស់យើងវិញ កាលដែលគាត់អាចធ្វើនេះ គួរគាត់ធ្វើតាំងពីពេលស៊ើបអង្កេតឯណោះ មិនត្រូវលើកឡើងនៅពេលនេះទេ។

[១៣:៤៣:៥៨]

**ប្រធានអង្គជំនុំ៖**

លោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍ មានបញ្ហាអ្វី ស្តាប់ភាគីរួចហើយ អញ្ជើញមានប្រសាសន៍បើសិនជាចង់មានប្រសាសន៍អីលើបញ្ហានេះឲ្យច្បាស់លាស់ ជារឿងដដែលកើតឡើង។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ខ្ញុំមិនមានមតិអ្វីពិសេសទេ ព្រោះថាអ្វីៗត្រូវលើកឡើងដោយសហមេធាវីនាំមុខរួចទៅហើយ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ បន្តនីតិវិធីទៅមុខទៀត។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** <តាមពិតទៅ> ខ្ញុំ<ស្ទើរតែ>បញ្ចប់សំណួរពាក់ព័ន្ធទៅនឹងប្រធានបទនេះ<ទៅ>ហើយ។ ប៉ុន្តែខ្ញុំមានសំណួរចុងក្រោយលោកដើមបណ្តឹងរដ្ឋប្បវេណី ហេតុអ្វីក៏លោកសម្រេចដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី <ម៉េច>មិននៅ<>ជាសាក្សី<ធម្មតាទៅ កាលនោះ>?

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ខ្ញុំគិតថា សំណួរនេះជាសំណួរមិនសមស្របទេ។ ដើមបណ្តឹងរដ្ឋប្បវេណី គាត់មានសិទ្ធិក្នុងការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ លោកមិនគួរណាសួរថា ហេតុអីបានជាគាត់ប្រើសិទ្ធិហ្នឹង ដើម្បីដាក់ពាក្យសុំធ្វើជាដើមបណ្តឹងរដ្ឋប្បវេណី មិនធ្វើជាសាក្សីទេ។

[១៣:៤៥:៥១]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំគិតថា ខ្ញុំមានសិទ្ធិសួរសំណួរនេះបានលោកចៅក្រម ដោយសារដើមបណ្តឹងរដ្ឋប្បវេណីនេះគាត់មិនបានដឹងថា គាត់មិនត្រូវសាកសួរនៅក្រោមសម្បថទេ ព្រោះគាត់ជាដើមបណ្តឹងរដ្ឋប្បវេណី។ បើមិនសួរនៅក្រោមសម្បថទេ តម្លៃនៃភស្តុតាងនៃរបស់គាត់ហ្នឹង វាមិនមានតម្លៃដូចគ្នាទៅនឹងសាក្សីនោះទេ។ <អ៊ីចឹង ខ្ញុំមិនដឹងថា គាត់ដឹង ឬអត់ទេ។> ខ្ញុំ<គ្រាន់តែឆ្ងល់ ថាតើគាត់អាចឆ្លើយសំណួរនឹងបាន ឬយ៉ាងណា> បើគាត់មិនឆ្លើយនឹងសំណួរខ្ញុំ <ក៏មិនថ្វីដែរ> ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

លោកមេធាវីការពារក្តី លោកចង់ផ្តល់ដំបូន្មានដល់ដើមបណ្តឹងរដ្ឋប្បវេណីមែនទេ អ្វីដែលលោកលើកឡើងហ្នឹង សំណួរលោកនោះ<ក្នុងនាមលោកជាមេធាវីការពារក្តី>? ខ្ញុំសូមសារភាពថា អ្វីដែលលោកនិយាយនោះ វាហួសពីភាពប្រាកដនិយមទៅហើយ។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំគ្រាន់តែស្វែងយល់ថា <មាន>មនុស្ស ២០.០០០នាក់ ធ្វើការនៅទំនប់ត្រពាំងថ្ម <ចុះ>ហេតុអ្វីក៏<មេធាវីដើមបណ្តឹងរដ្ឋប្បវេណីទៅ>សម្រេចជ្រើសរើសយកគាត់នេះ<មកនិយាយទៅវិញ។ វាដូច

ជាអព្ភូតហេតុសម្រាប់ខ្ញុំ។ ខ្ញុំកំពុងតែចង់ដឹងថាតើមានមូលហេតុអ្វីនៅពីក្រោយ ប៉ុន្តែខ្ញុំនឹង-->

**ប្រធានអង្គជំនុំ៖**

ដើមបណ្ដឹងរដ្ឋប្បវេណីមិនបាច់ឆ្លើយតបនឹងសំណួរហ្នឹងទេ ហើយយើងសូមបញ្ជាក់លោក វ៉ិចទ័រ កូប៉េ ថាបើលោកចង់សួរ គឺលោកសួរការិយាល័យសហចៅក្រមស៊ើបអង្កេត ហើយនិងអង្គជំនុំជម្រះអង្គបុរេជំនុំជម្រះ លោកអាចទៅសួរបាន ថាហេតុអីបានជាទទួលយកជាដើមបណ្ដឹងរដ្ឋប្បវេណី។

បាន១ ចប់ហើយ មានរឿងអីទៀត?

ដើមបណ្ដឹងរដ្ឋប្បវេណីមានបញ្ហាអីទៀតទេ លើបញ្ហាដដែលនេះ ឬក៏មានបញ្ហាផ្សេង។ ហាក់ដូចជាចម្រូងចម្រាសដើរទៅមុខអត់រួចទេ។

[១៣:៤៧:៤១]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

ខ្ញុំមិនចង់ឲ្យសវនាការយើងគាំងទេ ក៏ប៉ុន្តែខ្ញុំគ្រាន់តែចង់កត់សម្គាល់ក្នុងប្រតិចារឹកថា អ្វីដែលលើកឡើងដោយមេធាវីការពារក្ដី ខ្ញុំមិនយល់ស្របទេ ដែលគាត់ថាសក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណីមានទម្ងន់ស្រាលជាង<សក្ខីកម្មរបស់>សាក្សីនោះ។ អង្គជំនុំជម្រះនឹងសម្រេចករណីទៅតាមករណីដូច្នេះខ្ញុំចង់ឲ្យមានការកត់ត្រាទុក <ពីព្រោះយើងកំពុងតែដោះស្រាយនៅទីនេះ ជាមួយនឹង>យុត្តិសាស្ត្រតុលាការ<ម្ដងទៀតហើយ។>

**លោក វ៉ិចទ័រ កូប៉េ៖**

នេះគឺជាបញ្ហាហើយ ត្រង់កន្លែងនេះឯង។ បើសិនណាជាយើង ដោយសារតែយើងមិនមានសាក្សីឲ្យបានត្រឹមត្រូវសួរ ជាជាងសួរមកដើមបណ្ដឹងរដ្ឋប្បវេណីនោះ។

**ប្រធានអង្គជំនុំ៖**

លោកមានសំណួរសារធាតុអីសួរដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះដែរឬទេ លោក វ៉ិចទ័រ កូប៉េ?

អញ្ជើញផ្ដល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្ដីលោក ខៀវ សំផន!

[១៣:៤៨:៥៣]

**លោក អាកទ្វរ វែកកែន៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតប្រគល់វេទិកាជូនទៅសហភាគីរបស់ខ្ញុំ គឺមេធាវី គង់ សំអុន ប៉ុន្តែខ្ញុំគ្រាន់តែចង់<និយាយខ្លះ ដោយសារភាគីទាំងឡាយបានលើកឡើងសម្រាប់ជាប្រតិចារឹក។ នៅត្រង់នេះ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

យើងកំពុងសាកល្បងអំពីកម្រិតនៃដំណើរការនីតិវិធីរបស់តុលាការកូនកាត់នេះហើយ ហើយវា>ជាបញ្ហា<។> យើងមិនអាចនិយាយអំពីភាពអាចជឿជាក់របស់ដើមបណ្ដឹងរដ្ឋប្បវេណីនៅទីនេះបានទេ ពីព្រោះសហចៅក្រមស៊ើបអង្កេតមិនបានស្ដាប់ចម្លើយរបស់គាត់ទេ<ផង>។ អ៊ីចឹង <គាត់អាចត្រូវបានទទួលជាដើមបណ្ដឹងរដ្ឋប្បវេណីមុន ឬក្នុងដំណាក់កាលស៊ើបសួរ តែ>មិន<ត្រូវ>បានសួរអំពីបញ្ហាសារធាតុទៅលើដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ<ក៏ថាបាន>។ <នៅសវនាការថ្ងៃនេះ គឺ> យើងមិនអាចសួរអំពីភាពជឿជាក់បានទេ ពីព្រោះគាត់ត្រូវបានទទួលជាដើមបណ្ដឹងរដ្ឋប្បវេណីរួចទៅហើយ។ <គេក៏មិនអាចសួរដេញដោលអំពីទំនាក់ទំនងរវាងព្យសនកម្ម និងអង្គហេតុដែលកំពុងស្ដាប់បានឡើយ។> អ៊ីចឹង បើសិនជាមានសំណាង ហើយ<> សំណាងរួមបែបនេះ គឺខ្ញុំពិបាកយល់ដែរ។ ខ្ញុំមិនចោទអ្នកណាទេ <ទាំងអង្គជំនុំជម្រះ ទាំងភាគីផ្សេងៗ> ក៏ប៉ុន្តែចំពោះខ្ញុំ គឺថាយើងចេញហួសពីលក្ខណៈមួយដែលជាតុលាការកូនកាត់ទាល់ច្រកហើយនៅពេលនេះនោះ។ <ឥឡូវ ខ្ញុំសូមប្រគល់វេទិកាដល់សហភាគីរបស់ខ្ញុំ។>

**ប្រធានអង្គជំនុំ៖**

វិធានយើងបានអនុវត្តច្រើនមកហើយ ជិតចប់សំណុំរឿង០០២/០២ទៀតហើយ ហើយបានកន្លងផុតគឺ ០០២/០១។ ដូច្នេះ បទពិសោធន៍ដែលយើងបានអនុវត្តកន្លងមកនេះ យើងដូចជាមិនមានបញ្ហាអីទេ ទើបមកថ្ងៃនេះចេញរឿងប្លែកៗទើបតែថ្ងៃនេះទេ។

យើងបានប្រាប់ហើយអំមិញ បើថាចង់ដឹងច្បាស់លាស់ពីមូលហេតុអីហ្នឹង មិនសួរភាគីដែលជាម្ចាស់បណ្ដឹងទេ ទៅសួរអ្នកសម្រេច។

សូមអញ្ជើញលោកមេធាវី គង់ សំអុន!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។

[១៣:៥០:៤២]

**សួរដោយលោក គង់ សំអុន៖**

**ស៖** សូមជម្រាបសួរលោក ញឹប ហល់! ខ្ញុំមានសំណួរមួយចំនួនដើម្បីបញ្ជាក់បន្ថែម។ ព្រឹកមិញនេះ ខ្ញុំបានស្ដាប់ឮលោកឆ្លើយនឹងសំណួររបស់តំណាងអយ្យការទាក់ទងទៅនឹងការធ្វើប្រវត្តិរូបរបស់លោកនៅក្នុងពេលដែលលោកធ្វើការនៅទំនប់ត្រពាំងថ្ម។ សំណួរដំបូងដែលតំណាងអយ្យការអន្តរជាតិ

សួរអំពីថាលោកបានធ្វើប្រវត្តិរូបទេ? លោកឆ្លើយថា លោកអត់មានបានធ្វើប្រវត្តិរូបទេ ក៏ប៉ុន្តែលោកបានឆ្លើយបន្ថែម ដូចជាមិនថាលោកមិនបានយល់ ឬក៏មិនបានដឹងពីការធ្វើប្រវត្តិរូបនោះ ហើយក្រោយមកក៏មានការសួរនូវសំណួរនាំមុខដែលធ្វើឲ្យលោកឆ្លើយថា មានគេមកសួរឲ្យធ្វើប្រវត្តិរូប ប៉ុន្តែលោកមិនដឹងធ្វើយ៉ាងម៉េច។

អ៊ីចឹង ខ្ញុំចង់ឲ្យបញ្ជាក់សាឡើងវិញថា តើមានអ្នកមកសួរឲ្យលោកធ្វើប្រវត្តិរូប ឬមួយក៏មិនមានអ្នកមកសួរឲ្យលោកធ្វើប្រវត្តិរូបទេ នៅពេលដែលលោកធ្វើការនៅទំនប់ត្រពាំងថ្មនោះ?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីជាតិ!

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន ខ្ញុំចង់សុំជំទាស់អំពីបែបបទនៃការសួរបែបនេះ ដោយសារវែងអន្លាយមានភ្ជាប់ជាមួយនូវការសន្និដ្ឋាន ដោយមេធាវីខ្លួនឯងជាអ្នកសន្និដ្ឋាន ហើយឈានទៅដល់លើកជាសំណួរ ហើយដែលការសន្និដ្ឋាននេះអាចមិនមែនជាការសន្និដ្ឋានដែលត្រឹមត្រូវតាមអ្វីដែលដើមបណ្តឹងរដ្ឋប្បវេណីបាននិយាយ។ ដូច្នេះ ខ្ញុំសុំជំទាស់អំពីការសួរសំណួរបែបនេះ ហើយស្នើសុំឲ្យមានការសួរខ្លីៗទៅដល់ដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីឲ្យគាត់ងាយយល់ ហើយនិងអាចឆ្លើយបានត្រឹមត្រូវតាមសំណួរ។

បាទ សូមអរគុណលោកប្រធាន។

[១៣:៥៣:១៥]

**សួរដោយលោក គង់ សំអុន៖**

**ស៖** បាទ សូមអរគុណមិនថ្វីទេ។ សំណួរខ្ញុំអំមិញខ្លីរួចហើយ ប៉ុន្តែខ្ញុំសួរបញ្ជាក់ឡើងវិញទៅលើសំណួរដែលលោកបានឆ្លើយរួចហើយ ដោយសារចម្លើយរបស់លោកមិនភាពមិនច្បាស់លាស់តាមការស្តាប់របស់ខ្ញុំ ហើយដោយសារខ្ញុំជាអ្នកសួរ អ៊ីចឹង ខ្ញុំចង់សួរបញ្ជាក់លោកឡើងវិញឲ្យច្បាស់ថា តើអ្វីដែលជាចម្លើយរបស់លោក។ ខ្ញុំបានស្តាប់ឮច្បាស់ថាលោកមិនបានធ្វើប្រវត្តិរូបទេ។ នេះជាចម្លើយរបស់លោកដែលខ្ញុំបានស្តាប់។ ក៏ប៉ុន្តែ ក្នុងពេលដែលលោកមិនបានធ្វើប្រវត្តិរូបនេះថា មានអ្នកណាមកសុំឲ្យលោកធ្វើ ឬក៏គ្មានអ្នកមកសុំឲ្យលោកធ្វើទេ?

**លោក ញ៉ឹប ហល់៖**

**ឆ៖** បាទ រឿងប្រវត្តិរូបនេះ ដូចមិនដែលអ្នកណាមកសួរខ្ញុំថាឲ្យធ្វើប្រវត្តិរូបអីផង មិនដែល

មានទេ។

**ស៖** បាទ សូមអរគុណ។ នៅក្នុងចម្លើយរបស់លោកពីព្រឹកមិញដែរ លោកបានបញ្ជាក់អំពីការងារនៅលើទំនប់ត្រពាំងថ្មដែលលោកថា ដំបូងឡើយនៅពេលដែលលោកមកដល់ទំនប់ត្រពាំងថ្មហ្នឹង គឺលោកមកកាន់ស្ពានទី១ បាទគឺក្នុងពាក់កណ្តាលឆ្នាំ១៩៧៧។ អ៊ីចឹង ខ្ញុំចង់សួរលោកថា នៅពេលដែលលោកមកដល់ស្ពាន់ទី១ហ្នឹង លោកបានឃើញស្ថានភាពនៅទីតាំងស្ពានទី១នោះដូចម្តេចដែរ លោកអាចបញ្ជាក់បានទេ?

**ឆ៖** ស្ថានភាពនៅស្ពានទី១នោះ គឺខ្ញុំទៅដំបូង គឺដីមិនទាន់ពេញត្រចៀកស្ពានទេ ខ្ញុំត្រូវ -- កងខ្ញុំត្រូវចាក់នៅត្រចៀកស្ពាននោះឲ្យពេញ ត្រចៀកស្ពានខាងជើង ស្ពានទី១ បាទ។

**ស៖** អ៊ីចឹងខ្ញុំសូមបញ្ជាក់ថា លោក ក្រុមរបស់លោក ជាអ្នកធ្វើការនៅលើស្ពានទី១នេះតែម្តង ឬមួយនៅក្បែរស្ពានទី១?

**ឆ៖** គ្រាន់តែកងដែលចាក់ដីប៉ុណ្ណោះបាទ អត់មានកងជំនាញអីទេ កងចាក់ដី ឲ្យតែពេញដីគឺឈប់ចាក់ ពេញត្រចៀកស្ពាន។

**ស៖** អ៊ីចេះលោក សំណួររបស់ខ្ញុំ ៗសួរថាតើកងរបស់លោកធ្វើការ បានន័យថាជីកដី ចាក់ដីបំពេញហ្នឹងនៅលើស្ពានទី១ហ្នឹងតែម្តង ឬក៏ទីតាំងក្បែរស្ពានទី១ទេ លោកអាចបញ្ជាក់បានទេ?

**ឆ៖** ទីតាំងដែលធ្វើការគឺនៅត្រចៀកស្ពានអត់មាននៅលើស្ពានទេ បាទ។

**ស៖** បាទ បានន័យថានៅនឹងស្ពាន បានន័យថាជីកនៅក្បែរអា១គល់ស្ពានហ្នឹងជាការងារដែលក្រុមរបស់លោកត្រូវជីកដីបំពេញ តើអ៊ីចឹងមែនទេ?

**លោក ពេជ អង្គ៖**

បាទ តាមការពិតដោយសារការប្រើប្រាស់ពាក្យរបស់គាត់ទៅតាមស្រុកភូមិរបស់គាត់ គាត់ប្រើពាក្យត្រចៀកស្ពានសំដៅលើត្រចៀកស្ពាន។ បើនិយាយឲ្យចំគឺ "ត្រចៀកស្ពាន" ដែលអាចពាក្យនេះគាត់និយាយក្នុងភាសារបស់គាត់ យើងពិបាកយល់ ដូច្នេះហើយបានមានការសួរពីលោក គង់ សំអុន ច្រើនដង។ បាទ សូមអរគុណ។

[១៣:៥៨:០៦]

**លោក គង់ សំអុន៖**

**ស៖** បាទ អ៊ីចឹងខ្ញុំចង់សួរបញ្ជាក់ពាក្យថា "ត្រចៀកស្ពាន" តាមដែលលោកឆ្លើយហ្នឹង គឺបាន

ន័យថាទីតាំងដែលនៅជាប់ពីស្ពានទៅខាងជ្រុងនីមួយៗនៃទំនប់។ តើអ៊ីចឹងមែនទេ?

**លោក ញឹប ហល់៖**

**ឆ៖** បាទ គឺជ្រុងដែលនៅត្រចៀកស្ពានដែលគេរៀបស៊ីម៉ង់ត៍។

**ស៖** បាទ សូមអរគុណ។ តើលោកមានឃើញអ្វីខ្លះនៅក្បែរៗស្ពានហ្នឹង ជាទីតាំងការិយាល័យ ឬក៏ជារោងស្នាក់ ឬជាឃ្លាំងជាអីដែរទេ នៅក្បែរស្ពានហ្នឹង?

**ឆ៖** ខ្ញុំមិនបានចាប់អារម្មណ៍ ហើយក៏ភ្លេចដែរបាទ មិនឃើញ។

**ស៖** បាទ សូមអរគុណ។ ចុះលោកក្នុងក្រុមរបស់លោក កងរបស់លោកហ្នឹងនៅចម្ងាយប៉ុន្មានពីស្ពានហ្នឹងដែរ?

**ឆ៖** កន្លែងក្រុម កងខ្ញុំស្នាក់នៅពីត្រចៀកស្ពានទៅ ប្រហែលជា១គីឡូដី បាទ។

**ស៖** បាទ សូមអរគុណ។ ខ្ញុំសូមសួរសំណួរមួយទៀតទាក់ទងទៅនឹងពេលវេលាដែលលោករស់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ជាពិសេសនៅក្នុងដំណាក់ដំបូងបន្ទាប់ពីថ្ងៃ ១៧ មេសា ១៩៧៥ ដល់ពាក់កណ្ដាលឆ្នាំ -- ខែ១២ ឆ្នាំ១៩៧៦។ លោកបានឆ្លើយបញ្ជាក់ថា លោកត្រូវបានជម្លៀសពីភូមិកំណើតនៅភូមិចោលជ្រូក មកភូមិជ្រាប់ នៅឃុំជប់វារី។ ខ្ញុំចង់សួរថា តើលោករស់នៅក្នុងភូមិជ្រាប់ហ្នឹង ក្នុងពេលភ្លាមៗ បន្ទាប់ពីរំដោះភ្លាមៗហ្នឹងក្នុងរយៈពេលប៉ុន្មានដែរ?

**ឆ៖** ខ្ញុំពុំបានចាំពេលវេលាទេ គ្រាន់តែបាននៅយូរគ្រាន់ដែរបាទ មិនចាំពេលវេលាទេ។

[១៤:០១:៣៣]

**ស៖** បាទ តើលោកអាចចាំបានទេថា លោកនៅទីនោះរហូតទៅដល់ពេលដែលលោកទៅដាំកប្បាស នៅសាលាក្រហមទេ?

**ឆ៖** មិនមែនដាំកប្បាសទេនៅសាលាក្រហម គឺច្រូតស្រូវ បាទ។ ដាំកប្បាស គឺនៅភ្នំកងវ៉ា ច្រូតស្រូវនិងលីបាវនៅសាលាក្រហម។

**ស៖** បាទ សូមអរគុណ។ អ៊ីចឹងលោកអាចបញ្ជាក់បានទេថា នៅពេលដែលលោកចេញទៅភ្នំកងវ៉ា ដាំកប្បាសហ្នឹង គឺបន្ទាប់ពីលោកចេញពីភូមិជ្រាប់ថ្មីហ្នឹង តើអ៊ីចឹងមែនទេ?

**ឆ៖** ដែលខ្ញុំចេញពីភូមិជ្រាប់ថ្មី ក៏ខ្ញុំមិនដឹងថាចេញនៅពេលវេលាណា គ្រាន់តែចាំនៅឆ្នាំហើយ និងប្រហែលហ្នឹងខែដែល ខែ១២ ចេញពីច្រូតស្រូវនៅសាលាក្រហម ចេញភូមិជ្រាប់។

**ស៖** បាទ ឆ្នាំ លោកបញ្ជាក់ឆ្នាំមក?

**ឆ៖** ឆ្នាំ៧៦។

**ស៖** បាទ សូមអរគុណ។ ខ្ញុំចង់សួរថាអ្នកភូមិរបស់លោកនៅភូមិរោលជ្រូកហ្នឹង មានអ្នកភូមិផ្សេងទៀតមក ជម្លៀសមកភូមិជ្រាប់ថ្មីហ្នឹងដូចលោកដែរទេ?

**ឆ៖** មានពីរភូមិ គឺភូមិជប់ ហើយនិងភូមិរោលជ្រូក គោលដៅដែលគេឲ្យទៅ គឺពីរភូមិ។

**ស៖** បាទ សូមទោសប្រហែលជាខ្ញុំហៅឈ្មោះភូមិស្រុកកំណើតរបស់លោកខុស មិនមែនភូមិចោលជ្រូកទេ គឺភូមិរោលជ្រូក តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ ភូមិរោលជ្រូក មិនមែនចោលជ្រូកទេ។

**ស៖** បាទ សូមអរគុណ។ អ៊ីចឹងបានន័យថា អ្នកភូមិរោលជ្រូកទាំងអស់ហ្នឹង គឺជម្លៀសមកភូមិជ្រាប់ថ្មីដូចលោកដែរ អ៊ីចឹងមែនទេ?

**ឆ៖** បាទ គឺគ្មានអ្នកណាអាចនៅជាមួយគ្រួសារ ឬម្នាក់បានទេ។

[១៤:០៥:00]

**ស៖** បាទ សូមអរគុណ។ ដោយសារទីតាំងឃុំស្ថិតនៅក្នុងឃុំតែមួយ អ៊ីចឹងលោកជួយបញ្ជាក់ផលមើលថា ចម្ងាយពីឃុំ -- ពីភូមិរោលជ្រូក មកភូមិជ្រាប់ថ្មី ហ្នឹងមានចម្ងាយប៉ុន្មានគីឡូម៉ែត្រដែរ?

**ឆ៖** ប្រហែលជាប្រាំ ទៅប្រាំមួយរយ -- ប្រហែលជា ៥ ទៅ ៦គីឡូ ពីរោលជ្រូកទៅជ្រាប់ថ្មី។

**ស៖** បាទ សូមអរគុណ។ ខ្ញុំសូមបង្ហួសទៅខាងពេលវេលាខាងមុខបន្តិច ដោយសារខ្ញុំអត់បានដឹងពីចម្លើយរបស់លោកថា តើមុនឆ្នាំ៧៥ លោកធ្វើអ្វី? លោកអាចបញ្ជាក់បានទេថា មុនឆ្នាំ៧៥ លោកធ្វើការងារអ្វីដែរ?

**ឆ៖** មុនឆ្នាំ៧៥ ខ្ញុំនៅធ្វើស្រែ នៅភូមិកំណើត។

**ស៖** លោកធ្វើស្រែរហូត អត់មានការងារអ្វីក្រៅពីធ្វើស្រែទេ?

**ឆ៖** អត់មានទេ ធ្វើស្រែ។

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកសាក្សី។ លោកប្រធានខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោក ញឹប ហល់ ជាចុងក្រោយនេះ លោកអាចថ្លែងរៀបរាប់ប្រាប់អង្គសវនាការស្តាប់អំពីរឿងហេតុ ទំនាក់ទំនងទៅនឹងបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់លើជនជាប់ទាំងពីររូប នួន

ជា និង ខៀវ សំផន ដែលបានធ្វើឲ្យប៉ះពាល់ចំពោះលោកនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលនាំឲ្យប្តឹងសុំតាំងជាដើមបណ្តឹងរដ្ឋប្បវេណី ប្តឹងទាមទារសំណងជំងឺចិត្ត និងជាសមូហភាពពីជនជាប់ចោទ និងពីព្យសនកម្មដែលកើតមានចំពោះលោកជាអាទិ៍៖ ការខូចខាតរាងកាយ សម្ភារៈ ឬផ្លូវចិត្តនិងផលវិបាកដោយផ្ទាល់ពីបទឧក្រិដ្ឋ ជាព្យសនកម្មផ្ទាល់ខ្លួន និងបានកើតឡើងពិតប្រាកដរហូតដល់សព្វថ្ងៃនេះចំពោះខ្លួនលោក។

[១៤:០៨:០៨]

**លោក ញ៉ិប ហល់៖**

បាទ ចំពោះខ្ញុំដែលបានរស់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គឺថាមានជួបការលំបាក បាត់បង់នូវសាច់ញាតិ បាត់បង់នូវកម្លាំងពលកម្ម បាត់បង់នូវសុខភាព បាត់នូវសេរីភាព ជាពិសេសគឺបាត់បង់ឪពុកម្តាយ បងប្អូន។ ពេលមានការឈឺថ្កាត់ក៏គ្មានបងប្អូនញាតិមិត្ត ឬក៏សាច់សារលោហិតណាមួយមកសួរនាំ ឬក៏គ្មានថ្នាំសង្កូវអីនឹងលេប ហើយនិងលើកទឹកចិត្តទេ គឺដេកឈឺនៅម្នាក់ឯង រស់ ស្លាប់រស់ គឺតែម្នាក់ឯងប៉ុណ្ណោះឯងបាទ គឺបាត់បង់នូវបងប្អូន។ ពេលមកដល់ផ្ទះវិញ បងក៏បាត់ ឪពុកក៏ស្លាប់ ប្អូនក៏បាត់។ និយាយពីការឈឺចាប់រាប់មិនអស់ទេ បាទ មានតែប៉ុណ្ណឹង។

**ប្រធានអង្គជំនុំ៖**

មានៗអីទៀតទេលោកដើមបណ្តឹងរដ្ឋប្បវេណី?

**លោក ញ៉ិប ហល់៖**

បាទ ខ្ញុំគឺចង់មានសំណួរពីរ។ ទី១ ក្នុងរបបខ្មែរក្រហមនោះ គឺតើថ្នាក់ដឹកនាំរបបនោះមានដឹងពីប្រជាពលរដ្ឋទុក្ខលំបាកយ៉ាងណាដែរឬទេ? ហើយមួយទៀត តើឮថា អង្គការដាក់ទិស អង្គការនោះគឺជាអ្វី? បាទ ជាក្រុមមនុស្ស ឬក៏ជាអង្គភាព។ ឈ្មោះថា "អង្គការ" – អង្គការដាក់ទិសបាទ។ អង្គការនោះគឺជាអ្វី? សូមសំណួរពីរប៉ុណ្ណោះ។

[១៤:១២:០៦]

**ប្រធានអង្គជំនុំ៖**

លោកសួរតាមរយៈយើង តើសួរទៅអ្នកណាគេ?

**លោក ញ៉ិប ហល់៖**

សួរទៅខាងថ្នាក់ដឹកនាំខាងកម្ពុជាប្រជាធិបតេយ្យ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ប្រធានអង្គជំនុំ៖**

ស្នួរណាមួយ សួរទៅបុគ្គលណាមួយ*?*

**លោក ញឹប ហល់៖**

ទៅខាង នួន ជា បាទ។

**ប្រធានអង្គជំនុំ៖**

សួរតែ នួន ជា ម្នាក់ទេ ឬក៏សួរទាំងពីរនាក់? លោកសួរតែចំពោះលោក នួន ជា មួយរូប ឬក៏សួរទាំង ខៀវ សំផន ផង តាមរយៈប្រធានអង្គជំនុំជម្រះហ្នឹង?

[១៤:១៣:០៦]

**លោក ញឹប ហល់៖**

បាទ ខ្ញុំសួរថ្នាក់ដឹកនាំទាំងពីរនាក់ដែលបាននៅនេះឯងបាទ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោក ញឹប ហល់។ អង្គជំនុំជម្រះសូមជម្រាបលោកថា នៅក្នុងសវនាការកាលពីថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៥ បន្ទាប់ពីអង្គជំនុំជម្រះបានស្តាប់ជនជាប់ចោទទាំងពីរនាក់ឆ្លើយបញ្ជាក់អំពីការដែលពួកគាត់រក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតបនឹងសំណួរ។ អង្គជំនុំជម្រះកត់សម្គាល់ឃើញថាជនជាប់ចោទទាំងពីររូបនៅតែរក្សាជំហររបស់ខ្លួនក្នុងការអនុវត្តសិទ្ធិនៅស្ងៀមមិនឆ្លើយតបដដែល លើកលែងតែនិងរហូតដល់ពេលណាដែលអង្គជំនុំជម្រះទទួលបានព័ត៌មានជាក់ច្បាស់ផ្សេងពីជនជាប់ចោទ ឬមេធាវីការពារក្តីរបស់ជនជាប់ចោទ។ ហើយនៅក្នុងសវនាការនោះ អង្គជំនុំជម្រះក៏បានកំណត់ឲ្យជនជាប់ចោទ និង/ឬ សហមេធាវីការពារក្តីជនជាប់ចោទត្រូវមានភារកិច្ចទទួលខុសត្រូវក្នុងការជូនដំណឹងដល់អង្គជំនុំជម្រះ ឲ្យបានទាន់ពេលវេលានិងមានប្រសិទ្ធភាព ប្រសិនបើជនជាប់ចោទសម្រេចលះបង់សិទ្ធិនៅស្ងៀមមិនឆ្លើយតប ហើយយល់ព្រមឆ្លើយនូវសំណួរដែលអង្គជំនុំជម្រះ ឬភាគីពាក់ព័ន្ធនៅដំណាក់កាលណាមួយនៃកិច្ចដំណើរការនីតិវិធីសវនាការនេះ។ ហើយរហូតមកដល់ពេលនេះ អង្គជំនុំជម្រះមិនទាន់បានទទួលដំណឹងពីការផ្លាស់ប្តូរជំហររបស់ជនជាប់ចោទទាំងពីរនាក់ពីការសម្រេចលះបង់សិទ្ធិក្នុងការនៅស្ងៀមមិនឆ្លើយតប មកការឆ្លើយតបទៅនឹងសំណួរនៅឡើយទេ។ ហើយអង្គជំនុំជម្រះក៏សូមជម្រាបថា អង្គជំនុំជម្រះមិនអាចបង្ខំឲ្យជនជាប់ចោទលះបង់សិទ្ធិនៅស្ងៀមមិនឆ្លើយតបនោះបានឡើយ។ អានេះសូមលោកជ្រាប។

បាទ ហើយសវនាការនៅថ្ងៃនេះដល់ពេលឈប់សម្រាកហើយ គឺអង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃពុធ ទី២៦ ខែសីហា ឆ្នាំ២០១៥ ចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹក ហើយសវនាការនៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការដាក់បង្ហាញឯកសារគន្លឹះរបស់ភាគីចំពោះមុខអង្គជំនុំជម្រះ ពាក់ព័ន្ធទៅនឹងអង្គហេតុដែលបានធ្វើសវនាការកន្លងមក គឺ១) ការដ្ឋានការងារទំនប់១មករា, ២) ការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំង, ៣) ការដ្ឋានទំនប់ត្រពាំងថ្ម។ ហើយសូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាបានកំណត់នេះ។

អង្គជំនុំជម្រះ អរគុណលោក ញឹប ហាល់ សវនាការស្ដាប់សក្ខីកម្មរបស់លោកក្នុងឋានៈជាដើមបណ្ដឹងរដ្ឋប្បវេណី ឃើញថាដល់ទីបញ្ចប់ហើយ ហើយសក្ខីកម្មរបស់លោកនឹងអាចរួមវិភាគទានក្នុងការស្វែងរកការពិតក្នុងរឿងក្ដីនេះ។ វត្តមានរបស់លោកនៅ អ.វ.ត.ក លែងមានភាពចាំបាច់ទៀតហើយ លោកអាចវិលត្រឡប់ទៅកាន់លំនៅដ្ឋាន ឬក៏គោលដៅណាដែលលោកមានបំណងចង់ទៅបានហើយ។ សូមលោកមានសុខភាពល្អ មានសំណាងល្អ បានសេចក្ដីសុខ សេចក្ដីចម្រើន។ ហើយអង្គជំនុំជម្រះអរគុណ លោក យ៉ួន សារ៉ាត់ ជាបុគ្គលិកអង្គការ ធី.ភី.អូ ដែលបានជួយគាំទ្រ និងចូលរួមគាំទ្រដល់កិច្ចដំណើរការសវនាការស្ដាប់សក្ខីកម្មដើមបណ្ដឹងរដ្ឋប្បវេណី ញឹប ហាល់ ហើយសវនាការនេះ បានចប់ហើយនោះ ដូច្នេះលោកអាចសម្រាកបានហើយ។

ហើយបង្គាប់ឲ្យមន្ត្រីរដ្ឋបាលតុលាការ សម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សីនិងអ្នកជំនាញក្នុងការជូនលោក ញឹប ហាល់ វិលត្រឡប់ទៅកាន់លំនៅដ្ឋាន ឬក៏គោលដៅណាដែលគាត់មានបំណងចង់ទៅបានហើយ។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំង នាំខ្លួនជនជាប់ចោទទាំងពីររូប នួន ជា និង ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅថ្ងៃស្អែកវិញឲ្យបានមុនម៉ោងប្រាំបួនព្រឹក៕

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៤:១៦ នាទី)*